

របាយការណ៍សង្ខេបស្ដីពី

# ការវាយតម្លៃអំពី សុចរិតភាពធុរកិច្ចថ្នាក់ជាតិ

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

វិច្ឆិកា ២០១៧

**អង្គការតម្លាភាពកម្ពុជា**
អាសយដ្ឋាន៖ ផ្ទះលេខ ៣ ផ្លូវលេខ ៣៩០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១ ៤៤ ៣០/២៣ ២១ ៤២ ១១

គេហទំព័រក្នុងប្រទេស៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org

អង្គការតម្លាភាពកម្ពុជា គឺជាសាខាប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិដែលមានការទទួលស្គាល់យ៉ាងពេញលេញ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញដែលបានប្តេជ្ញាចិត្តបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់តាំងពីពេលនោះមក អង្គការតម្លាភាពកម្ពុជាបានក្លាយជាស្ថាប័នដ៏រឹងមាំមួយក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេស។

យើងធ្វើការរួមគ្នាជាមួយបុគ្គល និងស្ថាប័នគ្រប់ជាន់ថ្នាក់នានា រួមមាន៖ រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព លើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ឯកសារនេះត្រូវបានរៀបរៀងដោយមានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងប្រទេសស្វីស។ រាល់ទស្សនៈដែលបានលើកឡើងក្នុងឯកសារនេះពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ប្រទេសស៊ុយអែត ឬប្រទេសស្វីសឡើយ។

© ២០១៧ អង្គការតម្លាភាពអន្តរជាតិ។ រក្សាសិទ្ធគ្រប់បែបយ៉ាង។

SWEDEN

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

*Cover photo: ilf_ (www.flickr.com/photos/ilf_)*

# មាតិកា


មាតិកា 3

ពាក្យបំព្រួញ និងអក្សរកាត់.................................................... 4

តារាងតួលេខ.................................................... 4

បុព្វកថា 5

សេចក្តីថ្លែងអំណរគុណ 7

តួនាទីនៃសុចរិតភាពធុរកិច្ចក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ 8

១) ហេតុអ្វីចាំបាច់មានការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ?.................................. 9

២) វិធីសាស្ត្រស្រាវជ្រាវ.................................................... 9

៣) ពិន្ទុសូចនាករនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ.................................. 11

៤) ក្របខ័ណ្ឌពេលវេលា.................................................... 13

សេចក្តីសង្ខេប 14

១) គំនិតផ្តួចផ្តើមនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ.................................. 14

២) លទ្ធផលរកឃើញនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិនៅប្រទេសកម្ពុជា.............. 14

ក) សេចក្តីសង្ខេបស្តីពីការវាយតម្លៃវិស័យសាធារណៈ.................................. 16

ខ) សេចក្តីសង្ខេបស្តីពីការវាយតម្លៃវិស័យឯកជន.................................. 21

គ) សេចក្តីសង្ខេបស្តីពីការវាយតម្លៃសង្គមស៊ីវិល.................................. 24

៣) អ្វីដែលអ្នកអាចធ្វើបាន?.................................................... 25

ឯកសារយោង 26

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| ACL | Anti-Corruption Law | ច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ |
| ACU | Anti-Corruption Unit | អង្គភាពប្រឆាំងអំពើពុករលួយ |
| AML | Anti-Money Laundering | ប្រឆាំងការលាងសម្អាតប្រាក់ |
| ASYCUDA | Automated System for Customs Data | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ |
| BICA (Assessment) | Business Integrity Country Agenda (Assessment) | (ការវាយតម្លៃអំពី) សុចរិតភាពធុរកិច្ចថ្នាក់ជាតិ |
| CAFIU | Cambodian Financial Intelligence Unit | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| CCC | Cooperation Committee for Cambodia | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CSOs | Civil Society Organisations | អង្គការសង្គមស៊ីវិល |
| CSX | Cambodian Securities Exchange | ផ្សារមូលបត្រកម្ពុជា |
| EUROCHAM | European Chamber of Commerce | សភាពាណិជ្ជកម្មអឺរ៉ុប |
| FASMEC | Federation of Association of Small and Medium Enterprises of Cambodia | សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា |
| GDCE | General Department of Customs and Excise of Cambodia | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ |
| IFRS | International Financial Reporting Standards | បទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ |
| KICPAA | Kampuchea Institute of Certified Public Accountants and Auditors | វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា |
| LCE | Law on Commercial Enterprises | ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម |
| LEMNA | Law on Elections of Members of the National Assembly | ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ |
| LPE | Law on General Statute of Public Enterprises | ច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| NEC | National Election Committee | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| NISA | National Integrity System Assessment | ការវាយតម្លៃប្រព័ន្ធ សុចរិតភាពថ្នាក់ជាតិ |
| QIPs | Qualified Investment Projects | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| SMEs | Small and Medium Enterprises | សហគ្រាសធុនតូច និងមធ្យម |
| UNCAC | United Nations Convention Against Corruption | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ការប្រឆាំងអំពើពុករលួយ |
| WTO | World Trade Organisation | អង្គការពាណិជ្ជកម្មពិភពលោក |

# តារាងតួលេខ


| | | |
|---|---|---|
| ឧបករណ៍នៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ | រូបភាពទី ១ | ទំព័រទី ៨ |
| ក្របខ័ណ្ឌវាយតម្លៃ | រូបភាពទី ២ | ទំព័រទី ១០ |
| ក្របខ័ណ្ឌនៃការដាក់ពិន្ទុសូចនាករលើការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ | តារាងទី ១ | ទំព័រទី ១១ |

# បុព្វកថា

សេដ្ឋកិច្ចកម្ពុជាបានបន្តនូវកំណើនដ៏ខ្លាំងក្លា។ កំណើនសេដ្ឋកិច្ចនេះ មានសារៈសំខាន់សម្រាប់ប្រជាជនកម្ពុជា ដែលជាលទ្ធផល មានមនុស្សកាន់តែច្រើនឡើងៗ នឹងទទួលបានប្រយោជន៍ពីកំណើននេះ។ ការកើនឡើងនេះក៏បាននាំមកនូវការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់មួយចំនួនផងដែរ ដូចនេះ វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល ត្រូវតែត្រៀមលក្ខណៈ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទាំងនេះ។ ការវិវត្តន៍របស់ប្រទេសកម្ពុជា ពីសេដ្ឋកិច្ចដែលមានប្រាក់ចំណូលទាបទៅកាន់សេដ្ឋកិច្ចដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប តំណាងឱ្យការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងរបៀបដែលរាជរដ្ឋាភិបាលកម្ពុជានឹងទទួលបានប្រាក់ចំណូល និងបង្កើនការយកចិត្តទុកដាក់លើការប្រមូលពន្ធ។

ការផ្លាស់ប្តូរទាំងនេះ គឺជារឿងល្អសម្រាប់អ្នកប្រកបអាជីវកម្ម ប៉ុន្តែ ពួកគេក៏អាចមានការភ័យខ្លាចផងដែរ។ ការកើនឡើងនូវបទប្បញ្ញត្តិបង្កឱ្យមានការឈឺក្បាលកាន់តែច្រើនឡើងផងដែរសម្រាប់អាជីវកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម។ យ៉ាងណាមិញ ការបន្តការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌច្បាប់ដែលរឹងមាំនឹងបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នាយ៉ាងរស់រវើកសម្រាប់រាល់អាជីវកម្មទាំងអស់។

ដំណើរការអភិវឌ្ឍក៏បានមកដល់ចំណុចមួយដែលដំណើរការការិយាធិបតេយ្យ និងការចំណាយក្រៅផ្លូវការកំពុងតែបង្កការលំបាកដល់ការប្រកបអាជីវកម្មនៅកម្ពុជា។ យើងខ្ញុំសង្ឃឹមថា គំនិតផ្តួចផ្តើមថ្មីៗ ដូចជាការបង្កើនយន្តការតាមអនឡាញសម្រាប់ការចុះបញ្ជីអាជីវកម្ម ការបង់ពន្ធ និងនីតិវិធីនាំចូល និងនាំចេញនឹងធ្វើឱ្យឧបសគ្គមួយចំនួនក្លាយជារឿងអតីតកាល។ របាយការណ៍នេះបានផ្តល់អនុសាសន៍ជាអាទិភាពឱ្យមានយន្តការតាមអនឡាញបន្ថែមទៀតតាមដែលអាចធ្វើទៅបាន។ ក្របខ័ណ្ឌច្បាប់ក៏ត្រូវតែពង្រឹងផងដែរដើម្បីឱ្យស្របតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក និងផ្តល់ជាឆ្អឹងខ្នងដ៏ចាំបាច់សម្រាប់ប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធភាព។ យើងខ្ញុំបានធ្វើការកៀងគរមតិគាំទ្រជាយូរមកហើយដើម្បីឱ្យមានការអនុម័តច្បាប់ការពារបុគ្គលរាយការណ៍ ហើយយើងខ្ញុំបន្តជម្រុញឱ្យមានការបញ្ចេញជាសាធារណៈនូវសេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍។ លើសពីនេះទៀត យើងខ្ញុំបានផ្តល់អនុសាសន៍ឱ្យអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីធានាឱ្យបាននូវបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នា។ ការអនុវត្តក្របខ័ណ្ឌច្បាប់បច្ចុប្បន្នដែលគាំទ្រដល់សុចរិតភាពធុរកិច្ចមានការពិបាកក្នុងការវាស់វែង ពីព្រោះមានព័ត៌មានតិចតួចដែលអាចរកបានជាសាធារណៈ។ យើងខ្ញុំសូមអំពាវនាវឱ្យមានតម្លាភាពកាន់តែច្រើនឡើងលើវិធានការអនុវត្តច្បាប់ ដោយសារយើងខ្ញុំជឿជាក់ថា ការយល់ដឹងអំពីការអនុវត្តច្បាប់នឹងបញ្ចៀសមនុស្សពីការរំលោភច្បាប់។

វិស័យឯកជន ក៏ត្រូវតែចែករំលែកបន្ទុកមួយចំនួនដើម្បីបង្កើនបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នា និងបង្កើតការប្រកួតប្រជែងដោយយុត្តិធម៌សម្រាប់គ្រប់អាជីវកម្មទាំងអស់។ ក្រុមហ៊ុនក្នុងស្រុកត្រូវបានលើកទឹកចិត្តឱ្យបង្កើតយន្តការផ្ទៃក្នុងដ៏រឹងមាំ ដើម្បីបង្កើននូវសុចរិតភាពធុរកិច្ច និងអនុលោមភាពតាមច្បាប់របស់ពួកគេ។ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្មរបស់យើងខ្ញុំដែលជាយន្តការមួយក្នុងការផ្តល់ឱ្យក្រុមហ៊ុននានានូវគោលនយោបាយ និងនីតិវិធីដែលពួកគេត្រូវការដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ក្រុមហ៊ុនធំៗគួរតែបង្ហាញពីតម្លាភាពកាន់តែច្រើនថែមទៀតនៅលើគេហទំព័រ ឬនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ អំពីរចនាសម្ព័ន្ធគ្រប់គ្រង ការបង់ពន្ធ និងប្រាក់ចំណូលរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ក្រុមហ៊ុនគួរតែបញ្ជាក់ឱ្យបានច្បាស់អំពីគោលជំហររបស់ពួកគេស្តីពីការប្រឆាំងអំពើពុករលួយ។ ក្រុមហ៊ុនបរទេសក៏ត្រូវបង្ហាញពីតម្លាភាពនៃសកម្មភាពរបស់ពួកគេនៅក្នុងប្រទេសកម្ពុជាក្នុងរបាយការណ៍ប្រចាំឆ្នាំ និងនៅលើគេហទំព័ររបស់ពួកគេផងដែរ ហើយត្រូវតែគោរពច្បាប់របស់ប្រទេសកម្ពុជា។ សមាគមធុរកិច្ច និងសភាពាណិជ្ជកម្មបានផ្តល់សេវាកម្មដ៏មានអត្ថន័យ និងមានតម្លៃដ៏យូរលង់មកហើយ ដល់សមាជិករបស់ពួកគេ ហើយយើងខ្ញុំសង្ឃឹមថា ពួកគេនឹងដឹកនាំផ្លូវក្នុងការលើកកម្ពស់សុចរិតភាពធុរកិច្ចរបស់ពួកគេ។ ជាចុងក្រោយ អាជីវកម្មដែលមិនទាន់បានចុះបញ្ជី ត្រូវតែអនុវត្តឱ្យស្របតាមច្បាប់ និងត្រូវចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម (MoC)។ ខណៈពេលដែលកត្តានេះជាការគំរាមកំហែងដល់អាជីវកម្មជាច្រើន នេះគឺជាជំហាន

ដំបូងក្នុងការបង្កើតអាជីវកម្មមួយដែលស្អាតស្អំ និងកាត់បន្ថយភាពងាយរងគ្រោះ។

ចំពោះអ្នកដែលធ្វើការនៅក្នុងសង្គមស៊ីវិល យើងខ្ញុំសង្ឃឹមថា អ្នកនឹងធ្វើការជាមួយវិស័យសាធារណៈ និងឯកជន ដើម្បីលើកកម្ពស់បរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នាសម្រាប់រាល់អាជីវកម្មទាំងអស់។ សង្គមស៊ីវិលអាចធ្វើការជាមួយវិស័យឯកជន ក្នុងការលើកកម្ពស់អាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងមាននិរន្តរភាព ដោយសារវិស័យទាំងពីរនេះមានតម្លៃ និងគំនិតដ៏មានសារៈសំខាន់ដែលអាចផ្លាស់ប្តូរឱ្យគ្នាទៅវិញទៅមកបាន។ លើសពីនេះ សង្គមស៊ីវិលត្រូវរក្សាតួនាទីជាអ្នកឃ្លាំមើលរបស់ខ្លួន ហើយលើកឡើងនូវករណីរំលោភបំពានក្នុងវិស័យឯកជនដែលផ្តល់ផលប៉ះពាល់អាក្រក់ដល់សង្គម។ ជានិច្ចកាល នេះគឺជាតួនាទីដ៏មានតម្លៃសម្រាប់ទាំងប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិល។

វាគឺជាក្តីសង្ឃឹមរបស់យើងខ្ញុំដែលរបាយការណ៍នេះ នឹងផ្តល់នូវសកម្មភាព និងព័ត៌មានដ៏មានតម្លៃ និងមាន អត្ថន័យសម្រាប់ធ្វើដំណើរឆ្ពោះទៅមុខ។គោលបំណងនៃរបាយការណ៍នេះគឺពុំបានដាក់កំហុសទៅលើវិស័យ ឬស្ថាប័នណាមួយនោះទេ ប៉ុន្តែវាផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់កំណើន និងការរីកចម្រើនដោយចីរភាពរបស់កម្ពុជា។ ដោយពិនិត្យមើលដោយស្មោះត្រង់ថា ស្ថាប័នទាំងអស់ស្ថិតនៅក្នុងស្ថានភាពណា ពួកយើងអាចមើលឃើញយ៉ាងច្បាស់អំពីរបៀបដែលពួកយើងអាចឈានទៅមុខជាមួយគ្នាបាន។ យើងខ្ញុំសង្ឃឹមថា តាមរយៈការបង្កើនគណនេយ្យភាព តម្លាភាព និងសុចរិតភាពក្នុងគ្រប់វិស័យទាំងអស់ កម្ពុជាអាចបង្កើតបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នា និងទទួលបាននូវកំណើនដែលបង្កើតឱ្យមានឱកាសស្មើភាពគ្នាសម្រាប់សមាជិកទាំងអស់ក្នុងសង្គមនេះ។



លោក ព្រាប កុល
នាយកប្រតិបត្តិ
អង្គការតម្លាភាពកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ (BICA) អាចធ្វើទៅបាន តាមរយៈការងារប្រកបដោយការលះបង់ខ្ពស់របស់ទីប្រឹក្សាស្រាវជ្រាវ និងដៃគូពាក់ព័ន្ធរបស់យើងខ្ញុំទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិក្លាយជាការពិត។ កិច្ចខិតខំប្រឹងប្រែង និងជំនាញរបស់ពួកគេបានបង្កើតនូវរបាយការណ៍ស្រាវជ្រាវដ៏ល្អនេះដែលផ្តល់ជាព័ត៌មាន និងមានតម្លៃសម្រាប់អង្គការតម្លាភាពកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិសម្រាប់ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ ដែលមានដូចជា៖ ក្រុមហ៊ុនច្បាប់ Tilleke និង Gibbons សមាគមសហគ្រិនស្ត្រីកម្ពុជា សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម ធនាគារហ៊្វូលីព សារព័ត៌មានថ្មីៗ និងគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។ បន្ថែមពីនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម ដែលបានផ្តល់នូវមតិត្រឡប់ដ៏មានសារៈសំខាន់។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពដទៃទៀត ដែលបានផ្តល់មតិត្រឡប់លើរបាយការណ៍នេះ រួមមានសមាគមធុរកិច្ច សភាពាណិជ្ជកម្ម និងក្រុមហ៊ុននានា។ យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកជំនាញច្បាប់ លោក សុខ សំអឿន ដែលបានធ្វើការវិភាគផ្នែកច្បាប់ និងផ្តល់នូវការយល់ដឹងច្បាស់លាស់អំពីក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ។ សូមអរគុណដល់អង្គការស៊ីលការដែលបានអនុញ្ញាតឱ្យយើងខ្ញុំចែករំលែកនូវភាពជោគជ័យនៃកម្មវិធីរបស់អង្គការអ្នក។ នៅក្នុងគម្រោងទាំងមូល ទីប្រឹក្សាស្រាវជ្រាវរបស់យើងបានពិភាក្សាជាមួយសហគ្រាសធុនតូច និងមធ្យមជាច្រើនអំពីការអនុវត្តអាជីវកម្មរបស់ពួកគេ ហើយយើងខ្ញុំសូមអរគុណដល់សហគ្រិនទាំងអស់នោះ សម្រាប់ការចែករំលែកព័ត៌មានរបស់ពួកគេ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកស្រី Katja Bechtel លោកស្រី Suzanne Mulcahy និង លោកស្រី Anna Thayenthal មកពីលេខាធិការដ្ឋាននៃអង្គការតម្លាភាពអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលលើកដំបូង និងការគាំទ្រជាបន្តបន្ទាប់។

សូមអរគុណដល់ លោកស្រី Megan Karsh ដែលជាអ្នកជំនាញត្រួតពិនិត្យរបស់យើង និងជាអតីតអនុប្រធានកម្មវិធីបរិញ្ញាបត្រច្បាប់ជាភាសាអង់គ្លេសនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងនាយកប្រតិបត្តិនៃកម្មវិធីនីតិរដ្ឋនៃសាកលវិទ្យាល័យស្ទែនហ្វដ ដែលបានផ្តល់យោបល់ដ៏មានតម្លៃ។ សូមថ្លែងអំណរគុណដល់លោកស្រី Rachael Barat ជាអ្នកនិពន្ធកែសម្រួលឯកសារ និង លោកស្រី Erika Bryson ជាអ្នករចនារបាយការណ៍ ដែលបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការផ្តល់នូវឧបករណ៍រៀបចំរបាយការណ៍នេះគួរឱ្យចាប់អារម្មណ៍ និងគ្មានកំហុសអក្ខរាវិរុទ្ធ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកស្រី Samina Ullah និងលោក Nikola Kutin ដែលជាទីប្រឹក្សាស្រាវជ្រាវរបស់យើង និងអ្នកសរសេររបាយការណ៍ ដែលខិតខំធ្វើការដោយមិនចេះនឿយហត់ និងប្រកបដោយភាពច្នៃប្រឌិតដើម្បីបង្កើតរបាយការណ៍នេះ ព្រមទាំងប្រធានគ្រប់គ្រងកម្មវិធីពង្រឹងសុចរិតភាពធុរកិច្ច គឺលោកស្រី Sophia Aspesi Areias ដែលដឹកនាំរបាយការណ៍ផ្នែកស្រាវជ្រាវ និងពង្រាងអត្ថបទ។

របាយការណ៍នេះនឹងមិនអាចលេចរូបរាងឡើងបាននោះទេ បើគ្មានការគាំទ្រពីក្រុមការងារនៃអង្គការតម្លាភាពកម្ពុជារួមមាន កញ្ញា សរ សាន ចំពោះការគាំទ្រផ្នែករដ្ឋបាល លោកស្រី ឆាយ ពិដោរ ចំពោះគំនិតនិងការណែនាំ លោកស្រី ជា សុគន្ធា ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ លោក សៀង ម៉េងអួន ចំពោះការគាំទ្រផ្នែកធនធានមនុស្ស និងរដ្ឋបាល។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោក ប៊ិច ពិសី ដែលជានាយកកម្មវិធីដែលបានពិនិត្យឡើងវិញ និង ផ្តល់មតិយោបល់ត្រឡប់ដ៏មានតម្លៃ។ ចុងក្រោយបង្អស់ យើងខ្ញុំក៏សូមអរគុណដល់ លោក អ៊ឹម នរិន្ទ លោក សុខ សំបូរ លោក ប៉ែន រក្សា និងលោក Keith Yeoh ចំពោះការពិនិត្យមើលរបាយការណ៍នេះ និងការផ្តល់នូវមតិយោបល់ត្រលប់ដ៏មានតម្លៃ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយរបស់យើងខ្ញុំដូចជា ទីភ្នាក់ងារស៊ុីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ ទីភ្នាក់ងារអភិវឌ្ឍរបស់ប្រទេសស៊ុយអែត និងសហគមអឺរ៉ុប ចំពោះការគាំទ្រដ៏សប្បុរសរបស់ពួកគេ ព្រោះថាបើគ្មានការគាំទ្រទាំងនេះទេ របាយការណ៍នេះ ក៏មិនអាចធ្វើឡើងបានឡើយ។

# តួនាទីនៃសុចរិតភាពធុរកិច្ចក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

វិស័យឯកជននៅប្រទេសកម្ពុជាកំពុងធ្វើការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដោយសារប្រទេសនេះ បន្តមានការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងក្លា។ ទោះជាយ៉ាងណាក្តី ការប្រែប្រួលទាំងអស់នេះមិនមែនសុទ្ធតែវិជ្ជមាននោះទេ ពីព្រោះមានក្រុមហ៊ុនជាច្រើនក៏កំពុងទទួលបានការលើកទឹកចិត្តឱ្យចូលរួមក្នុងអំពើពុករលួយ។ ជារឿយៗ វិស័យឯកជនត្រូវបានគេមើលឃើញថាជាផ្នែកផ្គត់ផ្គង់នៃអំពើពុករលួយ បង្កើតការចំណាយក្រៅផ្លូវការដើម្បីសម្រួលឱ្យទទួលបានការអនុញ្ញាតិ អាជ្ញាប័ណ្ណ និងការប្រកាសពន្ធ។ ប៉ុន្តែចំពោះតួអង្គក្នុងវិស័យឯកជនដែលបានបដិសេធមិនចូលរួមប្រព្រឹត្តអំពើពុករលួយ អាចប្រឈមនឹងបរិយាកាសប្រកួតប្រជែងមិនស្មើភាពគ្នា ក្នុងការបង្កើតអាជីវកម្មរបស់ពួកគេ និងទទួលបានចំណែកទីផ្សារ។

ការកែលម្អសុចរិតភាពធុរកិច្ចប្រឈមមុខទាំងផ្នែកផ្គត់ផ្គង់ផង និងផ្នែកតម្រូវការនៃអំពើពុករលួយផង។ របាយការណ៍នេះធ្វើការស្វែងយល់បន្ថែមទៀតអំពីកត្តា និងសកម្មភាពនានាដែលអាចបង្កើនសុចរិតភាពធុរកិច្ច។ ដើម្បីដោះស្រាយផ្នែកទាំងពីរនៃសមីការអំពើពុករលួយ របាយការណ៍នេះធ្វើការវិភាគទៅលើ៖

១) បរិយាកាសអាជីវកម្មជាទូទៅ ដែលត្រូវបានបង្កើតឡើងដោយវិស័យសាធារណៈ

២) អន្តរកម្មនៃវិស័យឯកជនជាមួយវិស័យសាធារណៈ

៣) ឥរិយាបថរបស់វិស័យឯកជន

៤) តួនាទីរបស់សង្គមស៊ីវិលក្នុងការពិនិត្យមើលភាគីទាំងពីរ។

ជាដំបូងរបាយការណ៍នេះពិនិត្យលើក្របខ័ណ្ឌច្បាប់ដែលវិស័យឯកជនប្រតិបត្តិការ និងរបៀបដែលច្បាប់ពាក់ព័ន្ធទាំងនោះត្រូវបានគេអនុវត្ត។ យ៉ាងណាមិញ នេះគ្រាន់តែជាផ្នែកមួយនៃសាច់រឿងប៉ុណ្ណោះ។ របាយការណ៍នេះក៏ពិនិត្យលើឥរិយាបថរបស់វិស័យឯកជនទាក់ទងនឹងគោលនយោបាយ និងនីតិវិធីដែលពួកគេអនុវត្ត និងបទដ្ឋានដែលពួកគេជ្រើសរើសដើម្បីប្រកាន់ខ្ជាប់ផងដែរ។

រូបភាពទី ១: ឧបករណ៍នៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ



អង្គការតម្លាភាពអន្តរជាតិបានកំណត់និយមន័យសុចរិតភាពធុរកិច្ចថា “ការគោរពតាមបទដ្ឋានក្រមសីលធម៌ដែលទទួលស្គាល់ជាសកល ការអនុលោមទៅតាមទាំងស្មារតី និងលិខិតច្បាប់ និងបទប្បញ្ញត្តិ និងការលើកកម្ពស់តម្លៃស្នូលដែលមានការទទួលខុសត្រូវ (ពោលគឺ ភាពស្មោះត្រង់ យុត្តិធម៌ និងភាពជឿទុកចិត្ត)”[1]។ និយមន័យនេះបានដាក់សុចរិតភាពធុរកិច្ចឱ្យស្របទៅនឹងការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម ដែលក្រុមហ៊ុនឯកជនទាំងអស់ត្រូវធ្វើឱ្យលើសពីច្បាប់ ដើម្បីលើកកម្ពស់បុគ្គលិកឱ្យមានសុខុមាលភាពកាន់តែល្អ និងសហគមន៍មួយកាន់តែរឹងមាំឡើង។ វាមិនគ្រប់គ្រាន់នោះទេដោយគ្រាន់តែស្ថិតនៅក្នុងព្រំដែននៃច្បាប់ ក្រុមហ៊ុនទាំងអស់ត្រូវតែអនុវត្តតម្លៃនៃច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បីការពារ និងលើកកម្ពស់តម្លៃសង្គម។ ដូច្នេះការវិភាគនេះពិនិត្យមើលហួសពីអ្វីដែលជាតម្រូវការរបស់ច្បាប់ ដើម្បីស្វែងយល់បន្ថែមទៀតពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនទាំងឡាយចំពោះសុចរិតភាពធុរកិច្ច។

## ១.ហេតុអ្វីចាំបាច់មានការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ?

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ(BICA) របស់អង្គការតម្លាភាពអន្តរជាតិ គឺជាការវាយតម្លៃលើកដំបូងនៅក្នុងប្រទេសកម្ពុជា។ ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ គឺជារបាយការណ៍ដំបូងដើម្បីវិភាគបរិយាកាសសុចរិតភាពធុរកិច្ចទូទៅនៅក្នុងប្រទេស ដោយពិនិត្យមើលលើកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធទាំងអស់ ហើយវាគឺជាការវាយតម្លៃដ៏ទូលំទូលាយជាលើកដំបូងដែលមានគោលបំណងកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន។ របាយការណ៍នេះបង្កើតបាននូវភស្តុតាងរូបវន្ត និងចំណុចគោលដើម្បីវាយតម្លៃវឌ្ឍនភាពនាពេលអនាគត ក្នុងចលនាប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន។ លើសពីនេះទៀត ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិបានផ្តល់ជូននូវរបៀបវារៈសកម្មភាពរួមដែលនឹងត្រូវបានអនុម័តដោយផ្អែកលើរបកគំហើញនៃរបាយការណ៍នេះ។ ការសិក្សាដទៃទៀតក្នុងប្រទេសកម្ពុជាបានវិភាគអំពីបរិយាកាសធុរកិច្ចពីទស្សនវិស័យវិនិយោគ ឬអភិវឌ្ឍន៍ និងអាចផ្តល់ជាព័ត៌មានដ៏មានសារៈប្រយោជន៍។ ទាំងនេះរួមបញ្ចូលនូវៈ

- សន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ
- ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ (NISA) របស់អង្គការតម្លាភាពកម្ពុជា
- ការស្ទង់មតិអំពីសហគ្រាសរបស់ធនាគារពិភពលោក
- ភាពងាយស្រួលធ្វើអាជីវកម្មរបស់ធនាគារពិភពលោក

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិត្រូវបានរៀបចំឡើង ដើម្បីលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ ឱ្យប្រើរបកគំហើញនៃការស្រាវជ្រាវនេះ និងសហការគ្នាដើម្បីធ្វើការកែលម្អសុចរិតភាពធុរកិច្ច និងលើកកម្ពស់បរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នា។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិនៅប្រទេសកម្ពុជារបស់អង្គការតម្លាភាពអន្តរជាតិ ស្វែងយល់យ៉ាងលម្អិតពីកម្រិតនៃសុចរិតភាពធុរកិច្ចនៅក្នុងប្រទេស តាមរយៈការវិភាគលើប្រធានបទសំខាន់ៗចំនួនបីគឺ វិស័យសាធារណៈ វិស័យធុរកិច្ច និងសង្គមស៊ីវិល។ វិស័យទាំងបីនេះ ត្រូវបានបំបែកទៅជាសំណុំមួយនៃសូចនាករ ហើយសូចនាករនីមួយៗ ត្រូវបានបំបែកទៅជាសូចនាកររងមួយចំនួនទៀត (រូបភាពទី ១) ។

ការដាក់ពិន្ទុត្រូវបានបង្កើតឡើងសម្រាប់សូចនាករ និងសូចនាកររងនីមួយៗ។ វាមានសូចនាករសរុបចំនួន ១៥ និងសូចនាកររងចំនួន ៥១ (រូបភាពទី ២)។ សូចនាករចំនួន ៩ និងសូចនាកររងចំនួន ៣១ ពាក់ព័ន្ធនឹងវិស័យសាធារណៈ។ សូចនាករចំនួន ៥ និងសូចនាកររងចំនួន ១៧ ពាក់ព័ន្ធនឹងវិស័យឯកជន ខណៈដែលសូចនាករចំនួន ១ និងសូចនាកររងចំនួន ៣ ពាក់ព័ន្ធនឹងវិស័យសង្គមស៊ីវិល។

[1] សន្ធានុក្រមប្រឆាំងអំពើពុករលួយ

រូបភាពទី ២: ក្របខ័ណ្ឌវាយតម្លៃ




ទីប្រឹក្សាស្រាវជ្រាវទៅលើការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ បានប្រើប្រាស់ទាំងការស្រាវជ្រាវឯកសារដែលមានស្រាប់និងការសម្ភាសន៍អ្នកជំនាញដើម្បីវាយតម្លៃលើសូចនាករនិងសូចនាកររងទាំងអស់។គោលបំណងនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ គឺដើម្បីផ្តល់នូវក្របខ័ណ្ឌវិភាគទូលំទូលាយមួយដែលវាយតម្លៃលើកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធទាំងអស់ដើម្បីកែលម្អសុចរិតភាពធុរកិច្ច ដូច្នេះហើយក្របខ័ណ្ឌច្បាប់ សមត្ថភាពអនុវត្តច្បាប់ និងយុទ្ធសាស្ត្រ ព្រមទាំងគោលនយោបាយដែលត្រូវបានអនុវត្តដោយវិស័យសាធារណៈ វិស័យឯកជន និងវិស័យសង្គមស៊ីវិលត្រូវបានវាយតម្លៃ។ “ការស្រាវជ្រាវបែបគុណភាពបានពិនិត្យមើលព្រឹត្តិការណ៍ ឬបទពិសោធន៍ក្នុងបរិបទពីទស្សនវិស័យរបស់បុគ្គលដែលធ្លាប់ជួបប្រទះនឹងហេតុការណ៍ទាំងនោះ។ វិធីសាស្ត្រនេះអាចឱ្យទីប្រឹក្សាស្រាវជ្រាវស្វែងយល់ពីភាពស៊ីជម្រៅ និងភាពស្មុគស្មាញនៃទិដ្ឋភាពនានា ធ្វើការកំណត់ និងរៀបរាប់អំពីសមាសភាគ និងទំនាក់ទំនងរបស់ពួកវា ព្រមទាំងបង្កើតរូបភាពទាំងមូលដែលអាចពង្រឹង និងណែនាំការអនុវត្ត និងការស្រាវជ្រាវនាពេលអនាគត។ ការស្រាវជ្រាវបែបគុណភាពមានលក្ខណៈសមស្រប ដើម្បីឆ្លើយតបទៅនឹងសំនួរ ដូចជា “តើមានរឿងអ្វីកំពុងកើតឡើងនៅទីនេះ? តើខ្ញុំអាចពន្យល់ពីវាបានយ៉ាងដូចម្តេច?” ឬ ដើម្បីរៀបរាប់ពីរបៀបដែលមនុស្សរស់នៅ ឬដោះស្រាយជាមួយបទពិសោធន៍ជាក់លាក់”។[2]

លក្ខណៈចម្បងនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ គឺការវាយតម្លៃ និងការសង្កេតរបស់ទីប្រឹក្សាស្រាវជ្រាវ ត្រូវបានពិភាក្សា និងផ្ទៀងផ្ទាត់ជាមួយភាគីពាក់ព័ន្ធជាច្រើន។ ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនេះ ដែលមានស្ថាប័នចំនួន៧ចូលរួម មកពីវិស័យធនាគារ វិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យច្បាប់ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យសាធារណៈ។ ដូចមានចែងនៅក្នុងការបំពេញបន្ថែមលើ ដំណើរការវាយតម្លៃក្នុងក្របខ័ណ្ឌទស្សនទានសម្រាប់ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ[3] តួនាទីរបស់ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិមានដូចជា៖

- ផ្តល់យោបល់លើការស្រាវជ្រាវ សម្រាប់ការជ្រើសរើស ឬការបន្ថែមនូវប្រធានបទ និងការផ្សព្វផ្សាយ
- កំណត់អ្នកជំនាញដែលត្រូវសម្ភាសន៍ និងអ្នកចូលរួមសិក្ខាសាលា
- ផ្តល់មតិយោបល់ត្រឡប់លើលទ្ធផលនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ (មូលហេតុ និងដំណោះស្រាយដែលអាចកើតឡើង)

[2] Thompson & Walker, 1998

[3] TI-BICA Supplement 1: Assessment, 2016, p.12

- កំណត់អនុសាសន៍ជាយុទ្ធសាស្ត្រ
- ពិភាក្សាពីវិធីបំប្លែងអនុសាសន៍ជាយុទ្ធសាស្ត្រទៅជារបៀបវារៈនៃកំណែទម្រង់ដែលអាចប្រតិបត្តិបាន
- ពង្រឹងច្បាប់ និងទទួលយកភាគីពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ និងរបាយការណ៍ចុងក្រោយ
- លើកកម្ពស់របកគំហើញ និងអនុសាសន៍នៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ និង
- កសាងទំនាក់ទំនង និងបណ្តាញរបស់ដៃគូគម្រោង

កិច្ចប្រជុំបើកសម្ពោធក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ត្រូវបានធ្វើឡើងនៅដើមដំបូងនៃដំណើរការការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ ដើម្បីប្រមូលមតិយោបល់ត្រឡប់លើវិធីសាស្ត្រស្រាវជ្រាវ ។

## ៣. ពិន្ទុសូចនាករនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ

ដូចដែលបានរៀបរាប់ពីមុនមក សូចនាករ និងសូចនាកររងនីមួយៗ ត្រូវបានដាក់ពិន្ទុ ។ ប្រព័ន្ធកំណត់ពិន្ទុត្រូវបានផ្អែកលើបទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិនានា ដូចជា អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយឆ្នាំ២០០៤[4] អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងប្រទេសឆ្នាំ២០០៣ និងគោលការណ៍ណែនាំអន្តរជាតិផ្សេងៗទៀត ។ ដើម្បីសម្របសម្រួលការសិក្សាស្រាវជ្រាវ អង្គការតម្លាភាពអន្តរជាតិបានរៀបចំបញ្ជីសំណួរសម្រាប់សូចនាកររងនីមួយៗ ។[5] សូចនាករ និងសូចនាកររងនីមួយៗ ត្រូវបានគេវាយតម្លៃដោយប្រើមាត្រដ្ឋាន ចំនួន ៥ រួមមាន (0, ២៥, ៥0, ៧៥ និង ១00) ។ មានពិន្ទុត្រឹមតែ ៥ ប្រភេទប៉ុណ្ណោះដែលអាចដាក់បាន ។ ដើម្បីសម្របសម្រួលទំនាក់ទំនង ការដាក់ពិន្ទុត្រូវបានគេរៀបចំតាមសញ្ញា "ភ្លើងចរាចរ" ដែលងាយយល់ និងសាមញ្ញ (តារាងទី១) ។

តារាងទី ១: ក្របខ័ណ្ឌនៃការដាក់ពិន្ទុសូចនាករលើការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ

| មាត្រដ្ឋានពណ៌ | ពណ៌ | មតិយោបល់ |
|---|---|---|
| 0 | | ចម្លើយដែលត្រូវគ្នាទៅនឹងសំណួរដែលទទួលបានពិន្ទុ គឺ "គ្មានអ្វីសោះ" ។ ភស្តុតាងដែលប្រមូលបានសម្រាប់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបង្ហាញថា តម្រូវការមិនត្រូវបានបំពេញទាល់តែសោះ ។ |
| ២៥ | | ចម្លើយដែលត្រូវគ្នាទៅនឹងសំណួរដែលទទួលបានពិន្ទុ គឺ "ក្នុងកម្រិតកំណត់" ។ ភស្តុតាងដែលប្រមូលបានសម្រាប់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបង្ហាញថា មានតម្រូវការតិចតួចដែលត្រូវបានបំពេញ ឬថាមានតម្រូវការជាច្រើនត្រូវបានបំពេញក្នុងកម្រិតកំណត់ ។ |
| ៥0 | | ចម្លើយដែលត្រូវគ្នាទៅនឹងសំណួរដែលទទួលបានពិន្ទុ គឺ "ក្នុងកម្រិតខ្លះ" ។ ភស្តុតាងដែលប្រមូលបានសម្រាប់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបង្ហាញថា ប្រហែលពាក់កណ្តាលនៃតម្រូវការត្រូវបានបំពេញ ឬថាតម្រូវការភាគច្រើនត្រូវបានបំពេញនៅក្នុងកម្រិតខ្លះ ។ |
| ៧៥ | | ចម្លើយដែលត្រូវគ្នាទៅនឹងសំណួរដែលទទួលបានពិន្ទុ គឺ "ភាគច្រើន" ។ ភស្តុតាងដែលប្រមូលបានសម្រាប់លក្ខណៈវិនិច្ឆ័យវិនិច្ឆ័យនៃការវាយតម្លៃបង្ហាញថា មានតម្រូវការជាច្រើនត្រូវបានបំពេញ ឬថា តម្រូវការច្រើនបំផុតត្រូវបានបំពេញនៅក្នុងវិសាលភាពមួយធំ ។ |
| ១00 | | ចម្លើយដែលត្រូវគ្នាទៅនឹងសំណួរដែលទទួលបានពិន្ទុ គឺ "ពេញលេញ" ។ ភស្តុតាងដែលប្រមូលបានសម្រាប់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបង្ហាញថាទាំងអស់ ឬស្ទើរតែទាំងអស់នៃតម្រូវការត្រូវបានបំពេញ ។ |

ពិន្ទុត្រូវបានផ្តល់ឱ្យ និងត្រូវបានផ្ទៀងផ្ទាត់ តាមរយៈដំណើរការដ៏ទូលំទូលាយមួយ រួមមាន៖

- ការស្រាវជ្រាវឯកសារដែលមានស្រាប់: ទីប្រឹក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពអន្តរជាតិ បានធ្វើការស្រាវជ្រាវបន្ទាប់បន្សំ ដើម្បីឆ្លើយតបទៅនឹងសំនួរនីមួយៗសម្រាប់រាល់សូចនាកររងនីមួយៗ ។ ទីប្រឹក្សាស្រាវជ្រាវបានប្រមូលព័ត៌មានពីច្បាប់កម្ពុជា សារព័ត៌មានកម្ពុជា របាយការណ៍ពីស្ថាប័នអន្តរជាតិ ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្រុមហ៊ុនឯកជននានា និងឯកសារដែលបានបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដូចជា កាសែតខេមបូឌាដេលី និងកាសែតភ្នំពេញប៉ុស្តិ៍ ។ ពួកគេក៏បានប្រមូលនូវទិន្នន័យជាលេខពីសូចនាករអភិវឌ្ឍរបស់ធនាគារពិភពលោក ការស្ទង់មតិអំពីសហគ្រាសរបស់ធនាគារពិភពលោក ការិយាល័យស្ថិតិ (ក្រសួងមហាផ្ទៃ និង គមនាគមន៍នៃប្រទេសជប៉ុន) អង្គការតម្លាភាពអន្តរជាតិ និងប្រភពដទៃទៀត ។ ការសង្ខេបអំពីរបកគំហើញ មានផ្តល់ជូននៅក្នុងផ្នែកផ្តល់មតិយោបល់ នៅក្រោមសូចនាករនីមួយៗ ។

[4] UNCAC, Articles 14, 23.

[5] TI-BICA Supplement 2: Indicators, 2016

- ការសម្ភាសជាមួយអ្នកជំនាញ៖ កាលណាដែលមានទិន្នន័យបន្ទាប់បន្សំមិនគ្រប់គ្រាន់ដែលអាចរកបាន ដើម្បីផ្តល់ពិន្ទុ ទីប្រឹក្សាស្រាវជ្រាវបានធ្វើបទសម្ភាសជាមួយអ្នកជំនាញ។ អ្នកជំនាញនានាត្រូវបានគេសួរសំណួរដ៏ច្បាស់លាស់ ហើយក្នុងករណីខ្លះត្រូវបានគេស្នើសុំឱ្យវាយតម្លៃលើសូចនាកររងមួយចំនួនដែលមានមាត្រដ្ឋានចំនួន ៥ ដូចបានរៀបរាប់ខាងលើ។
- សេចក្តីព្រាងពិន្ទុ៖ បន្ទាប់ពីការស្រាវជ្រាវឯកសារដែលមានស្រាប់ ការសម្ភាសជាមួយអ្នកជំនាញ និងសេចក្តីយោងនានាសម្រាប់សូចនាករនីមួយៗ[6] ទីប្រឹក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពកម្ពុជា បានបង្កើតសេចក្តីព្រាងនៃពិន្ទុ និងមតិយោបល់ដែលពាក់ព័ន្ធនឹងសូចនាករ និងសូចនាកររងនីមួយៗ។ ទីប្រឹក្សាស្រាវជ្រាវបានឈរលើមូលដ្ឋានពិន្ទុដែលបានស្នើឡើង ទៅតាមការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយរបស់ពួកគេពីទិន្នន័យសរុបដែលប្រមូលបាន។ ដោយសារតែនេះគឺជាការវាយតម្លៃបែបគុណភាព កម្រិតនៃភាពលម្អៀង គឺមិនអាចចៀសផុតនោះទេ។ ប៉ុន្តែ អង្គការតម្លាភាពកម្ពុជា ក៏បានអនុវត្តជំហាននានា ដើម្បីគ្រប់គ្រងភាពលម្អៀងនេះ និងដើម្បីធានាថាពិន្ទុទាំងអស់ ត្រូវបានផ្តល់យ៉ាងត្រឹមត្រូវ។
- មតិយោបល់ត្រឡប់ពីក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ៖ អង្គការតម្លាភាពកម្ពុជា បានចែករំលែកពិន្ទុសូចនាករ និងយោបល់នានា ជាមួយសមាជិកនៃក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ដើម្បីបង្កើនសុចរិតភាពនៃរបាយការណ៍ស្តីពីការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ និងដើម្បីធានាឱ្យមានភាពជាក់ស្តែងនៃលទ្ធផល។ សិក្ខាសាលាពីរ ត្រូវបានគេរៀបចំឡើង ដើម្បីពិភាក្សាពីសូចនាករនីមួយៗ និងផ្តល់សុពលភាពលើពិន្ទុនីមួយៗ។ ពិន្ទុខ្លះ ត្រូវបានគេកែសម្រួលដោយផ្អែកលើអនុសាសន៍ និងមតិយោបល់ត្រឡប់របស់សមាជិកក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ។
- ការគណនាពិន្ទុចុងក្រោយ៖ ទីប្រឹក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពអន្តរជាតិ បានកែសម្រួលពិន្ទុដោយផ្អែកលើមតិយោបល់ និងធាតុចូលរបស់ ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ហើយបានបញ្ចប់របាយការណ៍។ អ្នកពិនិត្យមើលឡើងវិញនៃអ្នកជំនាញឯករាជ្យមួយរូប បានពិនិត្យកែសម្រួល និងបានផ្តល់យោបល់បន្ថែមលើរបាយការណ៍នេះ។



គួរបញ្ជាក់ថា សូចនាករខ្លះ មានពិន្ទុ 0 (ពណ៌ក្រហម) ពីព្រោះ គ្មានច្បាប់អនុវត្ត (ដូចជាច្បាប់ស្តីពីការបញ្ចុះបញ្ចូល)។ ទោះបីជា មាត្រាមួយចំនួនក្នុងបទប្បញ្ញត្តិ និងច្បាប់ដទៃទៀតមានការពាក់ព័ន្ធ ទីប្រឹក្សាស្រាវជ្រាវការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ បានផ្តល់ពិន្ទុតែទៅលើសូចនាករណាដែលមានច្បាប់ជាក់លាក់ដែលត្រូវបានគេប្រកាសឱ្យប្រើ។ ពិន្ទុ 0 មានន័យយ៉ាងសាមញ្ញថា គ្មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ពាក់ព័ន្ធនឹងសូចនាករ ដោយមិនបានន័យថា វិស័យឯកជន ឬសាធារណៈ មិនបានបំពេញសកម្មភាពយ៉ាងពេញលេញក្នុងការងាររបស់គេឡើយ។

[6] TI-BICA Supplement 2: Indicators, 2016

គំនិតនៃការដាក់ពិន្ទុ មិនមែនជាការស្វែងរកចំណុចអវិជ្ជមានរបស់អ្នកពាក់ព័ន្ធ ឬការផ្តល់យោបល់ថាពួកគេខ្វះ ឆន្ទៈក្នុងការកែលម្អសុចរិតភាពធុរកិច្ចនៅកម្ពុជានោះទេ។ ផ្ទុយទៅវិញ គោលបំណងនៃការដាក់ពិន្ទុ គឺដើម្បីចាប់ផ្តើមឱ្យមានការចូលរួម និង ការពិភាក្សាបន្តជាមួយភាគីពាក់ព័ន្ធនានា និងដើម្បីគូសបញ្ជាក់ពីច្បាប់ និងគំនិតផ្តួចផ្តើមនៃនីតិបញ្ញត្តិនានា ដែលត្រូវការការយកចិត្តទុកដាក់បន្ថែមទៀត។ តារាងដាក់ពិន្ទុបង្កើតចំណុចគោល ដើម្បីវាយតម្លៃវឌ្ឍនភាពបន្ត។ អង្គការតម្លាភាពកម្ពុជា នឹងធ្វើការតាមដាន តាមរយៈការដឹកនាំវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ ជាបន្តបន្ទាប់ទៀត នាពេលអនាគត។

## ៤. ក្របខ័ណ្ឌពេលវេលា

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ បានចាប់ផ្តើមឡើង ដោយការធ្វើសិក្ខាសាលាស្តីពី ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ នៅលេខាធិការដ្ឋានអង្គការតម្លាភាពអន្តរជាតិ នៅដើមខែកុម្ភៈ ឆ្នាំ២០១៧។ កិច្ចប្រជុំនៃក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិលើកដំបូង ត្រូវបានធ្វើឡើងនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ហើយការសិក្សាស្រាវជ្រាវ បានចាប់ផ្តើមភ្លាមៗបន្ទាប់ពីនេះ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិលើកទី២ ត្រូវបានធ្វើឡើងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីពិភាក្សាអំពីការដាក់ពិន្ទុដំបូងៗ ហើយការប្រជុំបន្ទាប់ទៀតនៃក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ត្រូវបានធ្វើឡើងនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៧។ របាយការណ៍នេះ ត្រូវបានបញ្ជូនទៅឱ្យអ្នកជំនាញ លោកស្រី Megan Karsh ពិនិត្យមើលឡើងវិញ ចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៧ ។

# សេចក្តីសង្ខេប

## ១. គំនិតផ្តួចផ្តើមនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ

គំនិតផ្តួចផ្តើមនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ គឺជាគំនិតផ្តួចផ្តើមថ្មីមួយ ដែលរៀបចំឡើងដោយអង្គការតម្លាភាពអន្តរជាតិ ក្នុងគោលបំណងកាត់បន្ថយអំពើពុករលួយ និងធ្វើឱ្យបរិយាកាសធុរកិច្ចជារួមកាន់តែប្រសើរឡើង។ គំនិតផ្តួចផ្តើមនេះ ចែកចែញជាពីរផ្នែក៖ ១) ការសិក្សាស្រាវជ្រាវអំពីបរិយាកាសសុចរិតភាពធុរកិច្ចក្នុងប្រទេសកម្ពុជា ដែលជាលទ្ធផលនៃរបាយការណ៍នៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ និង ២) ការអនុវត្តនូវលទ្ធផលរកឃើញសំខាន់ៗដែលបានមកពីរបាយការណ៍ ដើម្បីបង្កើតជារបៀបវារៈសម្រាប់ប្រតិបត្តិការមួយ ក្នុងគោលបំណងកែលម្អបរិយាកាសសុចរិតភាពធុរកិច្ច តាមរយៈសកម្មភាពរួមគ្នា។ ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ ត្រូវបានផ្អែកលើគោលគំនិតដែលថា កិច្ចសហការរវាងគ្រប់វិស័យទាំងអស់ រួមទាំងរដ្ឋាភិបាល និងសង្គមស៊ីវិល គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុត សម្រាប់កាត់បន្ថយអំពើពុករលួយនៅក្នុងបរិយាកាសធុរកិច្ច។

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ បង្កើតជាមូលដ្ឋានសម្រាប់របាយការណ៍នេះ។ ការវាយតម្លៃនេះ ពិនិត្យមើលលើអ្នកពាក់ព័ន្ធសំខាន់ៗនឹងបរិយាកាសសុចរិតភាពធុរកិច្ច ចំនួន ៣ រួមមាន វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល។ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានបែងចែក និងវិភាគដោយផ្អែកលើប្រធានបទចំនួន ១៥ និងសូចនាករចំនួន ៥១។ ការវាយតម្លៃបានដាក់ពិន្ទុ និងបានអនុវត្តតាមកូដពណ៌ (colour code) ទៅតាមសូចនាករ និងប្រធានបទនីមួយៗ ស្របតាមការអនុលោមរបស់អ្នកពាក់ព័ន្ធទៅនឹងសំណួរ។ លំដាប់ពិន្ទុមានដូចតទៅ៖ ពណ៌ក្រហម (0ពិន្ទុ) សម្រាប់ចម្លើយដែលឆ្លើយតបនឹង “គ្មានអ្វីសោះ” ពណ៌ទឹកក្រូច (២៥ពិន្ទុ) សម្រាប់ចម្លើយដែលឆ្លើយតបទៅនឹង ̂ក្នុងកម្រិតកំណត់” ពណ៌លឿង (៥0ពិន្ទុ) សម្រាប់ចម្លើយដែលឆ្លើយតបទៅនឹង “ក្នុងកម្រិតខ្លះ” ពណ៌បៃតង-លឿង (៧៥ពិន្ទុ) សម្រាប់ចម្លើយដែលឆ្លើយតបទៅនឹង “ភាគច្រើន” និងបៃតង (១00ពិន្ទុ) សម្រាប់ចម្លើយដែលឆ្លើយតបទៅនឹង “ពេញលេញ” ។

របាយការណ៍នៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ គឺជាប្រភេទនៃរបាយការណ៍ទីមួយ ដែលត្រូវបាន អនុវត្តនៅកម្ពុជា ហើយនឹងក្លាយជាចំណុចគោលសម្រាប់ការរីកចម្រើនបន្ថែមទៀតនៅក្នុងបរិយាកាសធុរកិច្ចជារួម។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយអង្គការតម្លាភាពកម្ពុជា។ ការវាយតម្លៃ គឺផ្អែកលើភស្តុតាងដែលប្រមូលបានពីប្រភពជាច្រើន ដូចជានីតិប្បញ្ញត្តិ របាយការណ៍ពាក់ព័ន្ធ ទិន្នន័យបឋម ភាគីពាក់ព័ន្ធ និងការ សម្ភាសជាមួយអ្នកជំនាញ។ ដំណើរការនេះ រួមបញ្ចូលទាំងការជ្រើសរើសក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ដែលតំណាងឱ្យពហុវិស័យនៃផ្នែកឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិល។ ក្រុមប្រឹក្សាយោបល់ថ្នាក់ជាតិ ត្រូវទទួលខុសត្រូវចំពោះការផ្តល់សុពលភាពលើពិន្ទុនៃការស្រាវជ្រាវ ហើយជូនដំណឹងអំពីអនុសាសន៍ដែលនឹងត្រូវប្រើប្រាស់ ដើម្បីផ្តួចផ្តើមសកម្មភាពរួមគ្នា។

## ២. របកគំហើញនៃការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិនៅប្រទេសកម្ពុជា

### វិស័យសាធារណៈ

ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិនៅក្នុងវិស័យសាធារណៈ លើកឡើងពីមុខងារនិងសមត្ថភាពនៃ ស្ថាប័នអភិបាលកិច្ចថ្នាក់ជាតិ និងតាមតំបន់ ដើម្បីលើកកម្ពស់បរិយាកាស ធុរកិច្ចឱ្យមានតម្លាភាព និងស្មើភាព ហើយកំណត់នូវចំនុចជាក់លាក់មួយចំនួន សម្រាប់ធ្វើការកែទម្រង់ និងធ្វើជាឯកសារយោង។ ដើម្បីវិភាគទៅលើ វិស័យសាធារណៈ ប្រធានបទសំខាន់ៗមួយចំនួនត្រូវបានសិក្សា រួមមាន ការប្រឆាំងអំពើពុករលួយ ការទទួលសំណូករបស់មន្ត្រីសាធារណៈ ការទទួលសំណូកពាណិជ្ជកម្ម ការលាងសម្អាតប្រាក់ ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជះបានឥទ្ធិពលមិនសមស្របទៅលើគណបក្សនយោបាយ ការការពារបុគ្គលរាយការណ៍ ស្តង់ដារគណនេយ្យ និងសវនកម្ម ការដាក់ដេញថ្លៃជាសាធារណៈ និងរដ្ឋបាលសារពើពន្ធ។

# ការវាយតម្លៃវិស័យសាធារណៈ



## ក. សេចក្តីសង្ខេបស្តីពីការវាយតម្លៃវិស័យសាធារណៈ

សុចរិតភាពធុរកិច្ចក្នុងវិស័យសាធារណៈ ត្រូវបានវិភាគលើបីផ្នែក គឺ: ១) ក្របខ័ណ្ឌច្បាប់និងគោលនយោបាយច្បាប់ដែលក្នុងនោះវិស័យសាធារណៈ និងឯកជន ធ្វើប្រតិបត្តិការ។ ២) ការអនុវត្តក្របខ័ណ្ឌនេះដោយវិស័យសាធារណៈ និង ៣) សមត្ថភាពសម្រាប់ការអនុវត្តក្នុងវិស័យសាធារណៈ និងអនុលោមភាពក្នុងវិស័យឯកជន។

ជំហានដំបូងក្នុងការវាយតម្លៃកម្រិត ដែលវិស័យសាធារណៈកំពុងរួមចំណែកដល់សុចរិតភាពធុរកិច្ចនៅកម្ពុជា គឺការកំណត់ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ។ ប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ២០០៤ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ (UNCAC) ក្នុងឆ្នាំ២០០៧។[7] ជាទូទៅក្របខ័ណ្ឌនីតិប្បញ្ញត្តិក្នុងស្រុកដែលគ្រប់គ្រងប្រតិបត្តិការធុរកិច្ចគឺស្របតាមស្តង់ដារបទដ្ឋានអន្តរជាតិ និងបានដាក់បញ្ចូលច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០។ ប្រទេសកម្ពុជាក៏បានប្រកាសឱ្យប្រើច្បាប់ទាក់ទងនឹងការទទួលសំណូករបស់មន្ត្រីសាធារណៈ ការទទួលសំណូកពាណិជ្ជកម្ម ការលាងសម្អាតប្រាក់ គណនេយ្យ និងសវនកម្ម ការជះឥទ្ធិពលមិនសមស្រប លទ្ធកម្មសាធារណៈ និងរដ្ឋបាលសារពើពន្ធ។ យ៉ាងណាក៏ដោយ ក្របខ័ណ្ឌច្បាប់ទាំងនេះ នៅមិនទាន់មានភាពទូលំទូលាយគ្រប់គ្រាន់ នៅឡើយទេ។ នៅមានច្បាប់ជាច្រើន ស្ថិតក្នុងដំណាក់កាលពង្រាង ឬមិនទាន់ត្រូវបានគេព្រាង នៅឡើយ។ លើសពីនេះទៀត ការអនុវត្តច្បាប់ដែលមានស្រាប់ ក៏នៅមានបញ្ហាជាច្រើន ហើយការផ្តន្ទាទោសចំពោះជនល្មើសក៏មានតិចតួចណាស់ដែរ។ ខាងក្រោមនេះ គឺជាទិដ្ឋភាពទូទៅនៃការវាយតម្លៃវិស័យសាធារណៈដោយផ្អែកលើក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន ក៏ដូចជាស្ថាប័នដែលទទួលខុសត្រូវចំពោះការអនុវត្តច្បាប់។

ការទទួលសំណូករបស់មន្ត្រីសាធារណជាតិ និងអន្តរជាតិ ត្រូវបានហាមឃាត់ដោយច្បាប់ប្រឆាំងអំពើពុករលួយ (ACL) ដោយយោងទៅតាមក្រមព្រហ្មទណ្ឌកម្ពុជា។ ការទទួលសំណូកពាណិជ្ជកម្ម ក៏ត្រូវបានហាមឃាត់ផងដែរ ហើយត្រូវបានចែងយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌ ជាជាងច្បាប់ប្រឆាំងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) គឺជាអង្គភាពនាំមុខគេ ដែលមានអាណត្តិស៊ើបអង្កេតលើពាក្យបណ្តឹងអំពីអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយ មានបំណងធ្វើអន្តរកម្មជាមួយតុលាការកម្ពុជា ដែលមានយុត្តាធិការក្នុងករណីកាត់ក្តី។[8] ការស្រាវជ្រាវបង្ហាញថាអង្គភាពប្រឆាំងអំពើពុករលួយ បានជម្រុញយ៉ាងសកម្មឱ្យមានដំណោះស្រាយផ្ទៃក្នុង ដើម្បីដោះស្រាយបញ្ហាពុករលួយជាមួយវិស័យឯកជន ជាជាងការស៊ើបអង្កេតជាសាធារណៈ។ មានបណ្តឹងអំពីការសូកប៉ាន់តិចតួចណាស់ នៅក្នុងប្រទេសកម្ពុជា។ យ៉ាងណាក៏ដោយ ចាប់តាំងពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ មានមន្ត្រីជាន់ខ្ពស់តែមួយរូបគត់ដែល ត្រូវបានផ្តន្ទាទោសពីបទទទួលសំណូក។[9] ចំនួនពាក្យបណ្តឹងអំពីអំពើពុករលួយ ដែលត្រូវបានផ្ញើទៅឱ្យអង្គភាពប្រឆាំងអំពើពុករលួយ បានថយចុះចាប់តាំងពីការបង្កើតអង្គភាពនេះ ហើយការថយចុះនេះ គឺដោយសារការបាត់បង់ជំនឿពីសាធារណជនចំពោះឯករាជ្យភាពនៃអង្គភាពនេះ។[10] ចំនែកឯតុលាការវិញ មានព័តិមានតិចតួចអំពីសមត្ថភាពរបស់តុលាការដែលអាចរកបាន ហើយប្រព័ន្ធតុលាការ ក៏ត្រូវបានគេរិះគន់ជារឿយៗ អំពីអំពើពុករលួយ ផងដែរ។[11]

ប្រទេសកម្ពុជា បានអនុម័តយ៉ាងរឹងមាំនូវច្បាប់ និងសេចក្តីប្រកាសនានាស្តីពីការប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយមានក្រុមពហុភាគីពាក់ព័ន្ធមួយ ដែលបានសម្របសម្រួលយុទ្ធសាស្ត្រប្រឆាំងការលាងសំអាតសម្អាតប្រាក់ (AML) សម្រាប់ប្រទេសកម្ពុជា។ ខណៈដែលក្របខ័ណ្ឌច្បាប់មានភាពរឹងមាំគួរសមក៏ដោយ ក៏កម្ពុជាទទួលរងគ្រោះពីប្រព័ន្ធតុលាការទន់ខ្សោយ និងអំពើពុករលួយជាប្រព័ន្ធ ដែលបានរារាំងការអនុវត្តន៍ការអនុវត្តប្រកបដោយប្រសិទ្ធភាព។[12] អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) បានប្រកាសជាសាធារណៈថា ខ្លួនខ្វះខាតសមត្ថភាពក្នុងការស៊ើបការណ៍អំពីការលាងសម្អាតប្រាក់ និងស្ថាប័នរាយការណ៍។[13] រហូតមកដល់បច្ចុប្បន្ន មានករណីប្រឆាំងនឹងការលាងសម្អាតប្រាក់ តែមួយប៉ុណ្ណោះ ត្រូវបានគេកាត់ទោសជាសាធារណៈ។[14]

ក្របខ័ណ្ឌច្បាប់ មានកម្រិតខ្លាំងណាស់ ទាក់ទងនឹងការឃុបឃិត ថ្វីបើមានករណីផ្សព្វផ្សាយជាសាធារណៈយ៉ាងច្រើនអំពីការឃុបឃិតនៅក្នុងឧស្សាហកម្មធនធានធម្មជាតិ ក៏ដោយ។ មានសេចក្តីព្រៀងច្បាប់មួយស្តីពីការប្រកួតប្រជែងដែលនឹងដោះស្រាយការបង្កើតឡើងនូវការកំណត់កូតាលើការដាក់កំហិតទិន្នផល និងការចែករំលែក ឬការបែងចែកទីផ្សារ ប៉ុន្តែច្បាប់នេះនៅ មិនទាន់បានអនុវត្តនៅឡើយទេនៅពេលធ្វើការបោះពុម្ពផ្សាយរបាយការណ៍នេះ។ ថ្វីបើមានច្បាប់ និងការអនុវត្តតិចតួច ប្រឆាំងនឹងការឃុបឃិតនៅថ្នាក់ជាតិ ក៏ដោយ ក៏នៅថ្នាក់

[7] WTO Cambodia; UNODC, UNCAC Ratification

[8] ACL, 2010. Chap. 6.

[9] The Phnom Penh Post, 6 January 2012

[10] The Phnom Penh Post. 5 January 2017

[11] TI-NISA Cambodia 2014, p. 6.

[12] US State Department, 2017

[13] The Phnom Penh Post, 5 October 2015

[14] The Cambodia Daily, 11 January 2017

ឃុំមានការរីកចម្រើនខ្លះៗផងដែរ។ ការអនុវត្តច្បាប់ក្នុងស្រុក បានអនុវត្តដាក់ទណ្ឌកម្មលើការដាក់បញ្ចូលអ្នកដេញថ្លៃដែលឃុបឃិតគ្នា ទៅក្នុងបញ្ជីខ្មៅ។[15]

បច្ចុប្បន្ននេះ ប្រទេសកម្ពុជា ខ្វះច្បាប់ការរាយការណ៍ ទោះបីមានសេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ ក៏ដោយ។[16] ក្រមព្រហ្មទណ្ឌកម្ពុជា និងច្បាប់ប្រឆាំងអំពើពុករលួយ ដាក់ការចោទប្រកាន់ ដែលចង់ព្យាបាទ ឬក្លែងក្លាយជាបទល្មើសព្រហ្មទណ្ឌ ដែលការណ៍នេះអាចបង្អាក់ដល់ការរាយការណ៍។[17] ច្បាប់ប្រឆាំងអំពើពុករលួយ មានខមួយស្តីពីការសម្ងាត់ សម្រាប់បុគ្គលដែលរាយការណ៍អំពីអំពើពុករលួយ។ ទោះជាយ៉ាងណាក៏ដោយ វាមានភាពមិនច្បាស់លាស់ថាតើមាត្រានេះនឹងការពារបុគ្គលរាយការណ៍ ពីការព្យាបាទ/គ្រោះថ្នាក់ទេ។

ស្តង់ដារគណនេយ្យ និងសវនកម្មរបស់កម្ពុជា មានលក្ខណៈស្របតាមបទដ្ឋាន របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS)។[18] គណនេយ្យករ ទីប្រឹក្សាផ្នែកពន្ធអាករ និងសវនករក្នុងស្រុក ទទួលបានវគ្គបណ្តុះបណ្តាលខ្ពស់ ហើយត្រូវបានគេចាត់ទុកថា ជាអ្នកមានវិជ្ជាជីវៈ និងមានឯករាជ្យ។ យោងតាមច្បាប់ ក្រុមហ៊ុននានា តម្រូវឱ្យធ្វើឯកសារប្រតិបត្តិការហិរញ្ញវត្ថុ ថ្វីបើសហគ្រាសធុនតូច និងមធ្យម (SMEs) ខ្លះត្រូវបានលើកលែង។ ក្រុមហ៊ុនទាំងអស់ ត្រូវតែចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ (GDT) និងក្រសួងពាណិជ្ជកម្ម ដែលជាអ្នកជួយក្នុងការអនុវត្តបទដ្ឋានសវនកម្ម និងធានារ៉ាប់រង។ ទីប្រឹក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពមិនអាចទទួលបានព័ត៌មានអំពីទណ្ឌកម្មដែលអនុវត្តដោយក្រុមប្រឹក្សាគណនេយ្យជាតិ ឬវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (KICPAA) បានទេ ហើយការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយលើស្តង់ដារគណនេយ្យ និងសវនកម្ម ក៏មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដែរ។ ការទទួលបានព័ត៌មានអំពីភាពជាម្ចាស់ផលប្រយោជន៍មួយចំនួន ក៏មានបញ្ហាក្រោមក្របខ័ណ្ឌសវនកម្ម និងធានារ៉ាប់រងពេលបច្ចុប្បន្ន ដោយសារការចុះបញ្ជីរបស់ក្រុមហ៊ុន មានលក្ខណៈដោយឡែកៗពីគ្នា ហើយព័ត៌មានរបស់ក្រុមហ៊ុនបន្ទាប់ពីបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ មកដល់ឆ្នាំ២០១៥។

ប្រទេសកម្ពុជាមានក្របខ័ណ្ឌតិចតួចបំផុតសម្រាប់ច្បាប់ស្តីពីការជះឥទ្ធិពលមិនសមស្របទៅលើនយោបាយ ដូចជាទំនាស់ផលប្រយោជន៍ និងគោលគំនិតនៃ “ការបញ្ចុះបញ្ចូល” នៅតែមានលក្ខណៈថ្មីបំផុត។ វិសោធនកម្មច្បាប់ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា (LEMNA) មានបទប្បញ្ញត្តិមួយចំនួនស្តីពីតម្រូវការរាយការណ៍សម្រាប់គណបក្សនយោបាយ រួមទាំងការដាក់ជូនសេចក្តីប្រកាសរបាយការណ៍ធនាគារមុនពេលបោះឆ្នោត។[19] ប៉ុន្តែសេចក្តីប្រកាសនេះ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ។ ខណៈពេលដែលការវិភាគទានអនាមិក មិនត្រូវបានហាមឃាត់នោះ គណបក្សទាំងអស់ ត្រូវរាយការណ៍អំពីប្រភពចំណូល និងចំណាយរបស់ពួកគេក្នុងអំឡុងពេលយុទ្ធនាការ។[20] មានព័ត៌មានតិចតួចបំផុតដែលអាចរកបាន អំពីការអនុវត្តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) (NEC) លើតម្រូវការថ្មីនេះ ហើយគជបគឺជាអង្គភាពតែមួយគត់ដែលមានការត្រួតពិនិត្យ។

បច្ចុប្បន្ន មិនមានច្បាប់ស្តីពីការបញ្ចុះបញ្ចូលទេ ហើយក៏គ្មានពង្រាងណាមួយ ត្រូវបានគេរៀបចំដែរ។

បច្ចុប្បន្ន ទំនាស់ផលប្រយោជន៏ ត្រូវបានគេដោះស្រាយក្រោមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ប៉ុន្តែបទប្បញ្ញត្តិបន្ថែមទៀត នឹងមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង។ ក្រោមប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីលទ្ធកម្ម សាធារណៈ មានផ្នែកមួយស្តីពីទំនាស់ផលប្រយោជន៍នៅក្នុងដំណើរការលទ្ធកម្មដែលកំណត់លក្ខខ័ណ្ឌ និងអាណត្តិដែលអ្នកដេញថ្លៃ ឬបុគ្គលិកណាមួយស្ថិតក្នុងដំណើរការលទ្ធកម្មត្រូវប្រកាសពីទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង។[21] ការដាក់ទណ្ឌកម្ម រួមទាំងការពិន័យព្រហ្មទណ្ឌ អាចរកបានក្រោមច្បាប់នេះ។ គ្មានស្ថាប័នត្រួតពិនិត្យតាមដានទំនាស់ផលប្រយោជន៍នៅដំណាក់កាលនេះទេ។

មានក្របខ័ណ្ឌច្បាប់ដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងដំណើរការលទ្ធកម្មសាធារណៈទាំងក្នុងបរិបទក្នុងស្រុក និងអន្តរជាតិ។ សៀវភៅណែនាំ (ប្រកាស) ប្រតិបត្តិការចំនួនពីរ មានទម្រង់បែបបទដេញថ្លៃ និងតម្រូវកិច្ចសន្យា ខណៈដែលច្បាប់មានប្រការមួយចំនួនស្តីពីការប្រឆាំងអំពើពុករលួយ។ ដំណើរការលទ្ធកម្មសាធារណៈកំណត់កម្រិតឱកាសរបស់អ្នកធ្វើការសម្រេចចិត្តក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធរបស់ពួកគេ ក្នុងអំឡុងពេលដំណើរ

[15] Expert Interview 13.[8] ACL, 2010. Chap. 6.

[16] The Phnom Penh Post, 30 June 2016

[17] ACL, 2010. Art. 17.

[18] KPMG, 2016

[19] LEMNA 2013, Article 37

[20] LEMNA 2013, Article 37

[21] Procurement Manual 1, Reg. 4.7.

ការដេញថ្លៃ។[22] អាជ្ញាធរវៀបចំកិច្ចសន្យាទាំងអស់ និងបុគ្គលិកនិយោជិតរបស់ពួកគេ ត្រូវតែប្រកាសចំពោះមុខច្បាប់ប្រឆាំងអំពើពុករលួយ ហើយអំពើពុករលួយនៅក្នុងលទ្ធកម្មសាធារណៈ ត្រូវត្រួតពិនិត្យតាមដានដោយអង្គភាពប្រឆាំងអំពើពុករលួយ។[23] ស្ថាប័នពិនិត្យតាមដាន និងសវនកម្មផ្ទៃក្នុង ប្រតិបត្តិការដោយឯករាជ្យក្រោមច្បាប់ ប៉ុន្តែពួកគេមិនអនុវត្តស្របគ្នាទូទាំងគ្រប់កម្រិតរបស់រដ្ឋាភិបាលឡើយ។ ក្រុមហ៊ុនត្រូវបានអនុញ្ញាតឱ្យចូលរួមដេញថ្លៃ ប្រសិនបើ ពួកគេ បានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍មួយដែលហាមឃាត់ការក្លែងបន្លំ អំពើពុករលួយ និងការឃុបឃិត។[24] ខណៈពេលដែលច្បាប់ ផ្ដល់នូវការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលអនុវត្តគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ ការលើកទឹកចិត្តទាំងនេះ មិនត្រូវបានអនុវត្តជាក់ស្ដែងនោះឡើយ។[25] ការដាក់ទណ្ឌកម្មរួមមាន ការដាក់ពិន័យជាសាច់ប្រាក់ ការចុះក្នុងបញ្ជីខ្មៅ និងការពិន័យព្រហ្មទណ្ឌ។

នាប៉ុន្មានឆ្នាំថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីបង្កើនតម្លាភាព និងកែលម្អការផ្ដល់សេវាកម្មរបស់ពួកគេ។[26] ទោះបីជាយ៉ាងនេះក្ដី ការស្នើសំណើសុំបង់ប្រាក់ក្រៅផ្លូវការនៅតែបន្ត ហើយទង្វើនេះ បានប្រឆាំងទៅនឹងបទប្បញ្ញត្តិបង់ពន្ធ ហើយការិយាធិបតេយ្យដែលមានកម្រិតខ្ពស់ ក៏អាចរារាំងដល់ផលិតភាព និងសុចរិតភាពធុរកិច្ចរបស់វិស័យឯកជនដែរ។[27] ឯកសារកំណែចុងក្រោយបំផុតនៃប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ទិន្នន័យគយ (ASYCUDA) ត្រូវបានអនុវត្តនៅក្នុងសាខា និងការិយាល័យពន្ធដារសំខាន់ៗចំនួន ៥៤[28] ដែលគ្របដណ្ដប់ប្រហែល ៨៧% នៃសកម្មភាពពាណិជ្ជកម្ម និងជួយកំណត់កម្រិតសកម្មភាពអន្តរកម្មជាបុគ្គល ដែលកត្តានេះ កំពុងកម្រិតចំណាយទូទាត់ក្រៅផ្លូវការ។ លើសពីនេះទៀត គ្មានយន្តការផ្លូវការណាមួយសម្រាប់ត្រួតពិនិត្យ និង វាយតម្លៃបុគ្គលិករបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ឡើយ។ ការលើកទឹកចិត្តស្ដីពីការបង់ពន្ធ អាចរកបានក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ហើយដល់ក្រុមហ៊ុនដែលបានចុះបញ្ជីជាមួយផ្សារហ៊ុនមូលបត្រកម្ពុជា (CSX) ។ ទោះជាយ៉ាងណាក៏ដោយ សហគ្រាសពហុជាតិ និងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនបានបើកចំហពីកិច្ចព្រមព្រៀងពន្ធដាររបស់ពួកគេជាសាធារណៈឡើយ។ ខណៈពេលដែល ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ កំពុងលើកទឹកចិត្តក្រុមហ៊ុន ឱ្យចុះបញ្ជី និងអនុវត្តតាមបទប្បញ្ញត្តិពន្ធគយនានា ក្រុមហ៊ុនជាច្រើនក៏នៅមានការស្ទាក់ស្ទើរក្នុងការធ្វើដូច្នេះ ដែលបណ្ដាលឱ្យក្រុមហ៊ុនដែលអនុលោមតាមច្បាប់ ទទួលភាពអយុត្តិធម៌ បើធៀបនឹងអាជីវកម្មដែលមិនបានចុះបញ្ជី។

[22] Procurement Manual 1, Reg. 6.2.1

[23] Procurement Manual 1, Reg. 4.3.5.

[24] Procurement Manual 1, Reg. 14.2.2.

[25] Procurement Manual 1, Reg. 17.1

[26] EUROCHAM, 2017

[27] WBG Enterprise Survey, 2016

[28] ASYCUDA Project

## អនុសាសន៍សម្រាប់វិស័យសាធារណៈ

អនុសាសន៍រយៈពេលខ្លី៖

- បង្កើនសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិច និងច្រកចេញចូលតែមួយ ដើម្បីកាត់បន្ថយបន្ទុកការិយាធិបតេយ្យ និងចំណាយទាក់ទងនឹងការធ្វើជំនួញនៅកម្ពុជា ជាពិសេសសម្រាប់សហគ្រាសធុនតូចនិងមធ្យម ហើយក៏បង្កើនការសម្របសម្រួល ការឆ្លើយតប និងគណនេយ្យភាពពីក្រសួងពាក់ព័ន្ធ។
- ធ្វើការចុះបញ្ជីអាជីវកម្មជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ជាសាធារណៈ រួមទាំងការទទួលបានព័ត៌មានអំពីភាពជាកម្មសិទ្ធិផលប្រយោជន៍។
- ពន្លឿនការប្រកាសឱ្យប្រើច្បាប់សំខាន់ៗដើម្បីបង្កើនតម្លាភាពនិងគណនេយ្យភាពដូចជាសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង សេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី ព្រមទាំងផ្តល់នូវចំណុចគោលប្រតិបត្តិការដែលស្របតាមបទដ្ឋានអន្តរជាតិសម្រាប់វិស័យសាធារណៈ និងវិស័យឯកជន។
- ចូលរួមជាមួយសមាគមធុរកិច្ច និងសង្គមស៊ីវិល ដើម្បីពង្រាងច្បាប់ស្តីពី ការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចការពារអតិថិជន និងកិច្ចសន្យាពាណិជ្ជកម្ម ក៏ដូចជាច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងក្រមស្តីពីការសាងសង់។
- ផ្សារមូលបត្រកម្ពុជា គួរផ្តល់ការបណ្តុះបណ្តាល និងលើកទឹកចិត្តដល់ក្រុមហ៊ុន ជាពិសេសសហគ្រាសធុនតូច និងមធ្យម អំពីប្រព័ន្ធអភិបាលកិច្ចសាជីវកម្ម និងសុចរិតភាពធុរកិច្ច។
- ពង្រឹងការតាមដាន និងត្រួតពិនិត្យលើលទ្ធកម្មសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាការជូនដំណឹងជាសាធារណៈអំពីកិច្ចសន្យា និងតម្លាភាពក្នុងលទ្ធផលនៃការផ្តល់កិច្ចសន្យាលើការដេញថ្លៃថ្នាក់ជាតិ។
- បើកចំហគ្រប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាសាធារណៈ និងផ្តល់នូវបញ្ជីអ្នកទទួលផល និងទិន្នន័យសរុបដែលទាក់ទងនឹងការលើកទឹកចិត្តស្តីពីពន្ធ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលស្ថិតនៅក្រោមកម្មវិធីនេះ។
- បើកចំហពីការបង់ពន្ធផ្លូវការទាំងអស់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ អគ្គនាយកដ្ឋានពន្ធដារ និងមន្ត្រីផ្សេងទៀតជាសាធារណៈ និងដាក់ទណ្ឌកម្មដល់មន្ត្រីណាដែលស្នើសុំការបង់ពន្ធក្រៅផ្លូវការ។ មិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរគម្រោងពន្ធគយ ដោយគ្មានការជូនដំណឹងទៅសាធារណជនជាមុន និងទាន់ពេលវេលា ។
- ផ្តល់ឱ្យនូវយន្តការដើម្បីដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងផ្តល់យន្តការមួយដល់ក្រុមហ៊ុនសម្រាប់រាយការណ៍អនាមិកអំពីបញ្ហា ឬការធ្វើខុសឆ្គងណាមួយដែលពាក់ព័ន្ធនឹងមន្ត្រីគយ និងពន្ធដារ។
- អនុវត្តវិសោធនកម្មថ្មីចំពោះក្រមពន្ធដារកម្ពុជា ឱ្យបានសមស្រប និងមានតម្លាភាព ក្រោមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៧ ទូទាំងវិស័យនានា ដើម្បីចៀសវាងការបង្កើតបរិយាកាសធុរកិច្ចដែលមិនមានការប្រកួតប្រជែង។ ផ្តល់នូវការបណ្តុះបណ្តាល ការលើកទឹកចិត្ត និងការគាំទ្របន្ថែមសម្រាប់អាជីវកម្មដើម្បីក្លាយជាអ្នកអនុលោមតាមច្បាប់ពន្ធដារ។
- បង្កើនភាពជាប់លាប់នៃការអនុវត្តការដាក់ពិន័យរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានផ្តល់ឱ្យក្រោមក្រមពន្ធដារ ហើយធានាឱ្យបាននូវយន្តការត្រឹមត្រូវ និងយន្តការប្តឹងតសម្រាប់រាល់ការដាក់ពិន័យដោយអគ្គនាយកដ្ឋានពន្ធដារ។
- កំណត់ឱ្យបានច្បាស់លាស់នូវអាជីវកម្មខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ដោយយោងតាមចំនួននិយោជិត និងចំណូល នៅទូទាំងក្រសួងពាក់ព័ន្ធនានា ដើម្បីឱ្យមានការរំពឹងទុកកាន់តែច្បាស់លាស់សម្រាប់ការអនុវត្តតាមតម្រូវការចុះបញ្ជីអាជីវកម្ម និងការបង់ពន្ធ។
- បង្កើនឯករាជ្យភាពរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយតាមរយៈការធ្វើវិសោធនកម្មច្បាប់ ទាក់ទងនឹងការតែងតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងថ្នាក់ដឹកនាំរបស់អង្គភាពប្រឆាំងអំពើពុករលួយដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបាយការណ៍ ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិរបស់អង្គការតម្លាភាពកម្ពុជា។

- បន្តបង្កើតបរិយាកាសសុចរិតភាពនៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយនិងទំនាក់ទំនងល្អរវាង អង្គភាពប្រឆាំងអំពើពុករលួយ និងសាធារណជន តាមរយៈ ១) ការផ្តល់យន្តការអនាមិកសម្រាប់បណ្តឹងប្រឆាំងនឹងអ្នកស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ (ពោលគឺ តាមរយៈយន្តការបណ្តឹងតាម អនឡាញដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ ២) ប្រកាសជាសាធារណៈអំពីដំណើរការទូទៅ នៃការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ ពាក់ព័ន្ធនឹងករណីអំពើពុករលួយ និង ៣)ផ្តល់យន្តការនៃដំណើរការយុត្តិធម៌ និងបណ្តឹងតវ៉ាត្រឹមត្រូវ ចំពោះការចោទប្រកាន់ជាសាធារណៈអំពីអំពើពុករលួយ ។
- បោះពុម្ពផ្សាយនូវខ្លឹមសារ និងលក្ខខណ្ឌនៃអនុស្សរណៈនៃការយោគយល់គ្នា ដែលអង្គភាពប្រឆាំងអំពើពុករលួយ បានចុះហត្ថលេខាជាមួយក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនអន្តរជាតិ និងក្រសួងនានា ។
- ពង្រឹងប្រសិទ្ធភាពនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះករណីសង្ស័យការលាងសម្អាតប្រាក់ ហើយសម្របសម្រួល ព្រមទាំងត្រួតពិនិត្យស្ថាប័នហិរញ្ញវត្ថុជាប្រចាំ ។

អនុសាសន៍រយៈពេលវែង៖

- ធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋសភាទាក់ទងនឹងថវិកាប្រចាំឆ្នាំ និងឱនភាពសារពើពន្ធជាសាធារណៈ និងចេញផ្សាយរបាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំអំពីថវិកាជាតិដោយអាជ្ញាធរសវនកម្មជាតិ ។
- បង្កើនមុខងារឯករាជ្យរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងការិយាល័យអគ្គអធិការកិច្ច ពីក្រសួងប្រតិបត្តិ និងស្ថាប័នរដ្ឋាភិបាលនានា ។
- អគ្គនាយកដ្ឋានពន្ធដារ គួររួមបញ្ចូលនូវការពង្រឹងជាវិជ្ជមានបន្ថែមទៀត សម្រាប់ក្រុមហ៊ុនដែលអនុលោមតាមច្បាប់ពន្ធដារ ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យម ខណៈពេលដែលបន្តធ្វើការងារជាមួយសមាគមធុរកិច្ច ដោយរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពីការចុះបញ្ជីអាជីវកម្ម និងការអនុវត្តពន្ធ ។
- ក្រសួងយុត្តិធម៌ និងរាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើវិសោធនកម្មច្បាប់ ដើម្បីតម្រូវឱ្យចៅក្រមនៅគ្រប់លំដាប់ថ្នាក់នៃតុលាការ បោះពុម្ពផ្សាយសេចក្តីសម្រេច និងហេតុផលរបស់ពួកគេ ហើយដើម្បីធានាថា បទដ្ឋាននានា ត្រូវបានបង្កើតឡើងសម្រាប់ដំណើរការនីតិវិធីតុលាការដោយចំហ ។
- បោះពុម្ពផ្សាយ និងអនុវត្តយន្តការមានតម្លាភាព និងច្បាស់លាស់មួយ សម្រាប់ជ្រើសរើស និងតែងតាំងមន្ត្រីតុលាការ និងចៅក្រម រួមទាំងលក្ខណៈវិនិច្ឆ័យជ្រើសរើស និងតែងតាំងបុគ្គលិក ត្រូវបានបោះពុម្ពផ្សាយដោយត្រឹមត្រូវ និងច្បាស់លាស់ ។
- ច្នៃប្រឌិតបង្កើតថ្មី និងអនុវត្តយន្តការមួយ សម្រាប់តាមដាន និងវាយតម្លៃការបំពេញការងាររបស់បុគ្គលិកនៅអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ សម្រាប់ភាពសមស្រប និងតម្លាភាព ដើម្បីកែលម្អការអនុវត្តការងារដោយយុត្តិធម៌ និងត្រឹមត្រូវរបស់មន្ត្រីពន្ធដារ និងគយទាំងអស់ ។
- ពង្រឹងច្បាប់ប្រឆាំងអំពើពុករលួយ នៅក្នុងច្បាប់ពន្ធដារ និងច្បាប់ស្តីពីគយ និងភ្ជាប់ច្បាប់ប្រឆាំងអំពើពុករលួយ ជាមួយបទប្បញ្ញត្តិពន្ធដារ និងគយ តាមរយៈអនុក្រឹត្យ ។
- បង្កើតមូលដ្ឋានទិន្នន័យច្បាប់ទាំងអស់នៅកម្ពុជាតាមអនឡាញ ដោយធ្វើការបកប្រែច្បាប់ថ្មីៗទាំងអស់ជាភាសាអង់គ្លេស ដើម្បីបង្កើនការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់នៅកម្ពុជា និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ដើម្បីតាមដានការអភិវឌ្ឍច្បាប់ និងការអនុវត្តរបស់ពួកគេ ។
- រាជរដ្ឋាភិបាលកម្ពុជាគួរធ្វើបច្ចុប្បន្នភាពច្បាប់ដែលមានស្រាប់តែហួសសម័យ ឬមិនឆ្លើយតបទៅនឹងទិសដៅប្រឆាំងអំពើពុករលួយ ដោយពិគ្រោះយោបល់ជាមួយវិស័យឯកជន និងសង្គមស៊ីវិល (ច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម ច្បាប់វិនិយោគ ច្បាប់សហគ្រាសសាជីវកម្ម ច្បាប់ស្តីពីពន្ធគយ និងច្បាប់ស្តីពីពន្ធដារ ។
- រាជរដ្ឋាភិបាលកម្ពុជា គួរធ្វើវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីរួមបញ្ចូលកាតព្វកិច្ចផ្លូវច្បាប់សម្រាប់ក្រុមហ៊ុននានា ដើម្បីបង្កើតក្រមសីលធម៌ និងបណ្តាញរាយការណ៍អនាមិក ។

## វិស័យឯកជន

# ការវាយតម្លៃវិស័យឯកជន




## ខ. សេចក្តីសង្ខេបស្តីពីការវាយតម្លៃវិស័យឯកជន

ក្រុមហ៊ុនពហុជាតិ និងបណ្តាក់ទុនរួមគ្នា ភាគច្រើនបង្កើតយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការប្រឆាំងអំពើពុករលួយ ប៉ុន្តែមានក្រុមហ៊ុនក្នុងស្រុកមួយចំនួនតូចប៉ុណ្ណោះ ដែលមានគោលនយោបាយគ្រប់គ្រងសុចរិតភាព។ ក្របខ័ណ្ឌច្បាប់នៅកម្ពុជា មិនតម្រូវឱ្យក្រុមហ៊ុនអនុវត្តតាមក្រមសីលធម៌ ឬបើកចំហជាសាធារណៈនូវគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ពួកគេនោះទេ។ វិស័យហិរញ្ញវត្ថុក្នុងស្រុក រួមទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផង ទំនងជាមានគោលនយោបាយ និងនីតិវិធីដែលបានបង្កើតឡើងភាគច្រើន និងបានផ្សព្វផ្សាយជាសាធារណៈ រួមទាំងក្រមសីលធម៌ផងដែរ។ អង្គភាពប្រឆាំងអំពើពុករលួយ បានផ្តល់ការគាំទ្រយ៉ាងច្រើនដល់វិស័យឯកជន តាមរយៈការបោះពុម្ពផ្សាយគោលការណ៍ណែនាំដល់ក្រុមហ៊ុននានា ដើម្បីចៀសវាងអំពើពុករលួយ និងការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិស័យឯកជនច្រើនជាង ៨០ អង្គភាព។[29]

រចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុង និងធានារ៉ាប់រងរបស់ក្រុមហ៊ុន អាស្រ័យលើទំហំប្រតិបត្តិការរបស់ពួកគេ។ ការស្ទង់មតិមួយរបស់សមាជិកសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) បានរកឃើញថា ៣៨% នៃសហគ្រាសធុនតូច និងមធ្យម មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយចំនួន។[30] រាល់ក្រុមហ៊ុនក្នុងស្រុកទាំងអស់ដែលបានចុះបញ្ជីស្របច្បាប់ តម្រូវដោយច្បាប់ឱ្យកត់ត្រាជាឯកសាររាល់ប្រតិបត្តិការហិរញ្ញវត្ថុនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនក្នុងស្រុកភាគច្រើនដែលជាក្រុមហ៊ុនតូចៗ មិនផ្តល់ហិរញ្ញប្បទានលើរចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងទេ ហើយសហគ្រាសខ្នាតតូច និងមធ្យមចំនួនច្រើនជាង ៥០% មិនមានគណៈកម្មាធិការ

[29] US State Department Investment Climate, 2017

[30] FASMEC Survey, 2017

សវនកម្មផ្លូវការឡើយ ។ សវនករឯករាជ្យមានអាជ្ញាប័ណ្ណ ប៉ុន្តែគុណភាពនៃក្រុមហ៊ុនមានការខុសគ្នាយ៉ាងខ្លាំង ។ សម្រាប់ក្រុមហ៊ុនធំៗ របាយការណ៍ហិរញ្ញវត្ថុ ជាទូទៅ ត្រូវបានធ្វើសវនកម្មដោយឯករាជ្យជារៀងរាល់ឆ្នាំ ប៉ុន្តែគ្មានច្បាប់ណាដែលតម្រូវឱ្យមានការវាយតម្លៃឯករាជ្យលើរចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងទេ ។[31] ក្រុមហ៊ុនដែលមានទំហំធំល្មម ដែលត្រូវធ្វើសវនកម្មឯករាជ្យ ជារឿយៗ បើកចំហរបាយការណ៍សវនកម្មរបស់ខ្លួន ។ មានព័ត៌មានតិចតួចបំផុតដែលអាចរកបាន អំពីថាតើក្រុមហ៊ុនណាទទួលបានការធានារ៉ាប់រងដោយឯករាជ្យ និងដោយស្ម័គ្រចិត្តលើការរៀបចំ និងការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយរបស់ពួកគេ ។ ក្រុមហ៊ុនកម្ពុជាភាគច្រើន មិនមានទម្លាប់បើកចំហកម្មវិធីប្រឆាំងអំពើពុករលួយ ប្រតិបត្តិការ ឬរចនាសម្ព័ន្ធគ្រប់គ្រងរបស់ពួកគេនោះទេ ដោយសារតែព័ត៌មាននេះមិនតម្រូវដោយច្បាប់នោះឡើយ ។

ទីប្រឹក្សាស្រាវជ្រាវរបស់អង្គការតម្លាភាពអន្តរជាតិ បានធ្វើការស្ទង់មតិលើក្រុមហ៊ុនចំនួន ៤៧ (ក្រុមហ៊ុនក្នុងស្រុកចំនួន ៣១ និងក្រុមហ៊ុនអន្តរជាតិចំនួន ១៦) ដោយផ្អែកលើព័ត៌មានដែលរកបាននៅលើគេហទំព័ររបស់ពួកគេ (ដោយអនុវត្តតាមវិធីសាស្ត្រ TRAC សូមមើលឧបសម្ព័ន្ធ ក) ។ គោលបំណងនៃការស្ទង់មតិនេះគឺដើម្បីស្វែងយល់ពីការអនុវត្តជាទូទៅ នៃការបើកចំហព័ត៌មានធានារ៉ាប់រង ។ ក្នុងចំណោមក្រុមហ៊ុនក្នុងស្រុកចំនួន ៣១ មានតែ ៤ ក្រុមហ៊ុនប៉ុណ្ណោះ ដែលបានចែករំលែកព័ត៌មានអំពីកម្មវិធីប្រឆាំងអំពើពុករលួយរបស់ពួកគេ ឬការអនុលោមតាមច្បាប់ក្នុងស្រុក បើប្រៀបធៀបទៅនឹងក្រុមហ៊ុនបរទេសដែលមានចំនួន ១២ ក្នុងចំណោម ១៦ក្រុមហ៊ុនបានចែករំលែកអំពីកម្មវិធីនេះ ។នេះអាចបញ្ជាក់បានថា ក្រុមហ៊ុនក្នុងស្រុកមិនមានគោលនយោបាយទាំងនេះ ឬមួយវិញទៀត ពួកគេភាគច្រើនចង់រក្សាគោលនយោបាយជាលក្ខណៈផ្ទៃក្នុង ជាជាងការបើកចំហព័ត៌មានទាំងនេះជាសាធារណៈ ។ ផ្ទុយទៅវិញ ក្រុមហ៊ុនបរទេស និងក្រុមហ៊ុនពហុជាតិដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ជាទូទៅ មានគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយកម្រិតខ្ពស់ជាង និងអាចរកបានជាសាធារណៈ ។

មធ្យោបាយសំខាន់មួយសម្រាប់ក្រុមហ៊ុនឯកជនក្នុងការចូលរួមក្នុងគំនិតផ្តួចផ្តើមពហុភាគី លើការប្រឆាំងអំពើពុករលួយ គឺតាមរយៈសមាគមធុរកិច្ចសម្រាប់ក្រុមហ៊ុនក្នុងស្រុក និងសភាពាណិជ្ជកម្មសម្រាប់ក្រុមហ៊ុនបរទេស ។ សភាពាណិជ្ជកម្មអឺរ៉ុប (EUROCHAM) មានគណៈកម្មាធិការពន្ធដារ ហើយធ្វើការជាមួយអាជ្ញាធរដើម្បីផ្តល់ព័ត៌មានឥតគិតថ្លៃដល់សមាជិករបស់ខ្លួន ។[32] វេទិកាវិស័យរាជរដ្ឋាភិបាល-ផ្នែកឯកជន គឺជាគំនិតផ្តួចផ្តើមមួយរវាងនាយករដ្ឋមន្ត្រី និងខុទ្ទកាល័យ នឹងសហគមន៍ធុរកិច្ច ដែលសម្របសម្រួលដល់គណៈកម្មាធិការក្រុមការងារមួយចំនួន ក្នុងការសម្របសម្រួលរវាងសមាគមធុរកិច្ច សភាពាណិជ្ជកម្មកម្ពុជា និងខុទ្ទកាល័យ ។ ថ្វីបើ មានគំនិតផ្តួចផ្តើមទាំងនេះ និងការកែលម្អរបស់ក្រសួងជាច្រើនក៏ដោយ ក៏មានតម្រូវការចាំបាច់ក្នុងការបង្កើតយន្តការទំនាក់ទំនងរវាងធុរកិច្ច និងក្រសួងនានា រួមទាំងការអនុញ្ញាតឱ្យមានសេវាសាធារណៈ តាមប្រព័ន្ធអនឡាញបន្ថែមទៀត ។

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ (LPE) និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម (LCE) បានគូសបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុននៃប្រទេសកម្ពុជា ដែលតម្រូវឱ្យនាយក និងមន្ត្រីទាំងឡាយ ធ្វើសកម្មភាពប្រកបដោយសេចក្តីស្មោះត្រង់ និងធ្វើការសម្រេចចិត្តក្នុងបំណងល្អ ។[33] បទប្បញ្ញត្តិបន្ថែមគូសបញ្ជាក់អំពីតម្រូវការអភិបាលកិច្ចសាជីវកម្មនិងការបង្កើតយន្តការការពារសិទ្ធិរបស់អ្នកពាក់ព័ន្ធ ។[34] យោងតាមការស្រាវជ្រាវ ខណៈពេលដែលមានបទប្បញ្ញត្តិនានា ដើម្បីគ្រប់គ្រងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល មានព័ត៌មានតិចតួចបំផុតដែលអាចរកបានជាសាធារណៈទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកលើបទសម្ភាសន៍ជាមួយអ្នកជំនាញ បទប្បញ្ញត្តិទាំងនេះ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ តាមដែលអាចធ្វើទៅបាន ។

[31] FASMEC Survey, 2017

[32] EUROCHAM,Tax Committee, 2017

[33] LCE, 2005, Article 127

[34] Prakas No. 013, Article 3

## អនុសាសន៍សម្រាប់វិស័យឯកជន

អនុសាសន៍រយៈពេលខ្លី៖

- សភាពាណិជ្ជកម្ម និងសមាគមធុរកិច្ច គួរតែបើកចំហព័ត៌មានអំពីអត្ថប្រយោជន៍នានានៃការចូលរួមយ៉ាងជិតស្និទ្ធជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដល់សមាជិករបស់ពួកគេ ជាពិសេស សារៈសំខាន់នៃកិច្ចការពារសម្រាប់អ្នកដែលនឹងរាយការណ៍ទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយ ។
- សមាគមធុរកិច្ច និងសភាពាណិជ្ជកម្ម គួរតែបន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុចរិតភាពធុរកិច្ច និងការអនុវត្តរបស់សាជីវកម្ម (ដូចជា ក្រមវិជ្ជាជីវៈ ក្រមសីលធម៌ បណ្តាញរាយការណ៍ប្រឆាំងអំពើពុករលួយ គោលនយោបាយប្រឆាំងអំពើពុករលួយ) រួមទាំងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការបង្កើត និងបណ្តុះបណ្តាលការអនុវត្តការងារល្អៗ ។
- សមាគមធុរកិច្ច គួរតែកំណត់ចំណុចគោលសម្រាប់សុចរិតភាពធុរកិច្ចនៅក្នុងឧស្សាហកម្មនីមួយៗ ហើយទទួលស្គាល់ និងផ្តល់រង្វាន់ដល់ក្រុមហ៊ុនដែលសម្រេចបានលទ្ធផលល្អ ។
- ក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិគួរបង្កើតបណ្តាញរាយការណ៍ដោយអនាមិក និងដែលត្រូវបានការការពារ ដើម្បីលើកទឹកចិត្តនិយោជិតគ្រប់កម្រិតទាំងអស់ ឱ្យរាយការណ៍ករណីអំពើពុករលួយ ឬការធ្វើខុសឆ្គងផ្សេងៗទៀត ។
- ក្រុមហ៊ុនគួរតែធានានូវការអនុលោមតាមច្បាប់ដោយធ្វើការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ។ សមាគមធុរកិច្ចគួរតែលើកទឹកចិត្តដល់ដំណើរការនេះ និងជួយនៅពេលណាដែលអាចធ្វើទៅបាន ។
- ក្រុមហ៊ុនក្នុងស្រុក ជាពិសេស សហគ្រាសធុនតូច និងមធ្យម គួរតែបង្កើនសុចរិតភាពធុរកិច្ច តាមរយៈការអនុវត្តគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង រួមទាំង ក្រមវិជ្ជាជីវៈ បណ្តាញរាយការណ៍ និងវិធានការប្រឆាំងអំពើពុករលួយផ្សេងៗទៀត ។
- ក្រុមហ៊ុនដែលត្រូវបានតម្រូវឱ្យធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ គួរតែធ្វើសវនកម្ម និងផ្សព្វផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំដែលបានធ្វើសវនកម្មជាសាធារណៈ ។
- ក្រុមហ៊ុននានា គួរបើកចំហអំពីគោលនយោបាយ និងសកម្មភាពប្រឆាំងអំពើពុករលួយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងនៅលើគេហទំព័ររបស់ពួកគេ ។

អនុសាសន៍រយៈពេលវែង៖

- សមាគមធុរកិច្ច គួរលើកទឹកចិត្តក្រុមហ៊ុនឱ្យយល់ពីតម្លៃនៃការអនុវត្តគណនេយ្យស្អាតស្អំ និងតម្លៃបន្ថែមដោយសេវាកម្មគណនេយ្យជំនាញវិជ្ជាជីវៈ ។
- ក្រុមហ៊ុននានា គួរតម្រូវឱ្យមានការប្រឆាំងនឹងអំពើពុករលួយដោយហ្មត់ចត់ពីដៃគូ និងអ្នកផ្គត់ផ្គង់របស់ពួកគេ និងបង្កើតមូលដ្ឋានទិន្នន័យនៃក្រុមហ៊ុនស្អាតស្អំ ។
- ក្រុមហ៊ុនឯកជន គួរតែផ្តល់នូវបណ្តាញបន្ថែមទៀត ដើម្បីរាយការណ៍ពីករណីអំពើពុករលួយ ។ ការរាយការណ៍ជាពិសេស ទៅអង្គភាពប្រឆាំងអំពើពុករលួយ គឺមិនគ្រប់គ្រាន់ទេ ។
- សភាពាណិជ្ជកម្ម គួរលើកកម្ពស់ និងផ្តល់យោបល់ដល់ក្រសួងនានាក្នុងការធ្វើសេចក្តីព្រាង និងការប្រកាសឱ្យប្រើច្បាប់ដែលពាក់ព័ន្ធ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី និងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង និងធ្វើបច្ចុប្បន្នភាពច្បាប់ដែលមានស្រាប់តែហួសសម័យ ឬមិនឆ្លើយតបទៅនឹងទិសដៅប្រឆាំងអំពើពុករលួយ ។ កិច្ចការនេះ គួរតែត្រូវបានពិគ្រោះយោបល់ជាមួយវិស័យឯកជន និងសង្គមស៊ីវិល ។
- សមាគមពាណិជ្ជកម្ម គួរតែលើកកម្ពស់កិច្ចសន្ទនាអំពីបញ្ហាប្រឈមនានាដែលបានកើតឡើងក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ដើម្បីលុបបំបាត់ភាពអាម៉ាស់ដែលទាក់ទងនឹងការរាយការណ៍ និងការនិយាយអំពីបញ្ហាក្នុងការធ្វើអាជីវកម្ម ។

## សង្គមស៊ីវិល

# ការវាយតម្លៃវិស័យសង្គមស៊ីវិល




## គ. សេចក្តីសង្ខេបស្តីពីការវាយតម្លៃសង្គមស៊ីវិល

អង្គការសង្គមស៊ីវិល (CSOs) មានវត្តមានយ៉ាងរឹងមាំនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែមានតែអង្គការសង្គមស៊ីវិលមួយចំនួនតូចដែលបានយកចិត្តទុកដាក់លើសុចរិតភាពធុរកិច្ច។ ថ្មីៗនេះ មានគំនិតផ្តួចផ្តើមខ្លះៗផ្តោតលើសុចរិតភាពធុរកិច្ច និងការប្រកបអាជីវកម្មដោយការទទួលខុសត្រូវ។ ក្នុងឆ្នាំ២00៨ ក្រុមហ៊ុនក្នុងស្រុក និងបរទេសចំនួន ៤0 បានគាំទ្រដល់គំនិតផ្តួចផ្តើមធុរកិច្ចស្អាតស្អំនៅក្នុងប្រទេសកម្ពុជារបស់អង្គការ ផេក (PACT) ដែលបានអំពាវនាវឱ្យមានការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ក្នុងការចៀសវាងការសូកប៉ាន់ និងការលក់ផលិតផលក្លែងក្លាយ និងគ្មានសុវត្ថិភាព ព្រមទាំងដំណើរការប្រក បដោយយុត្តិធម៌ និងសុចរិតភាព ហើយដើម្បីជម្រុញការកែទម្រង់បរិយាកាសធុរកិច្ច។ នៅក្នុងឆ្នាំ២០១៤ អង្គការតម្លាភាពកម្ពុជា បានបើកដំណើរការកម្មវិធីពង្រឹងសុចរិតភាពធុរកិច្ចរបស់ខ្លួនដែល ផ្តោតលើការបង្កើននូវតម្លាភាព គណនេយ្យភាព និងសុចរិតភាពនៅក្នុងបរិយាកាសធុរកិច្ច។[35] ជាពិសេស កម្មវិធីសុចរិតភាពធុរកិច្ចបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនដើម្បីកែលម្អរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ជាចុងក្រោយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) បានបើកដំណើរការកម្មវិធីប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចក្នុងឆ្នាំ២០១៧ ដែលធ្វើការលើកកម្ពស់អន្តរកម្មរវាងសង្គមស៊ីវិល និងវិស័យឯកជន។[36]

ជាប្រវត្តិសាស្រ្ត អង្គការសង្គមស៊ីវិល មិនធ្លាប់បានធ្វើជាអ្នកឃ្លាំមើលវិស័យឯកជន ជុំវិញបញ្ហាសុចរិតភាពធុរកិច្ចនោះទេ ប៉ុន្តែពួកគេមានសមត្ថភាពធ្វើដូច្នោះ។ អង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ត្រូវបានដាក់ឱ្យបម្រើជាអ្នកឃ្លាំមើល ដោយសារមានក្រុមសង្គមស៊ីវិលជាច្រើនបាន និងកំពុងធ្វើដូច្នេះរួចទៅហើយ សម្រាប់វិស័យសាធារណៈ។ តួនាទីឃ្លាំមើល គឺមានសារៈសំខាន់ខ្លាំងណាស់ ដោយសារតែប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសកម្ពុជាភាគច្រើន មិនអាចដើរតួនាទីប្រកបដោយគណនេយ្យភាពបានទេ ដោយសារប្រព័ន្ធផ្សព្វផ្សាយជាច្រើនត្រូវបានភ្ជាប់ជាមួយគណបក្សកាន់អំណាច។ គិតត្រឹមឆ្នាំ២០១៧ បណ្តាញទូរទស្សន៍ចំនួន ៧ ក្នុងចំណោម ១០ ត្រូវបានគ្រប់គ្រងដោយបុគ្គលដែលជាប់ពាក់ព័ន្ធនឹងគណបក្សកាន់អំណាច ដែលជាមន្រ្តីរដ្ឋាភិបាល ឬជាទីប្រឹក្សារបស់រដ្ឋាភិបាល។[37] បណ្តាញសារព័ត៌មានផ្សេងទៀត មិនមានបំណងផ្សព្វផ្សាយអំពីអំពើពុករលួយនោះទេ ពីព្រោះពួកគេត្រូវបានគាំទ្រដោយការផ្សាយពាណិជ្ជកម្មពីក្រុមហ៊ុនឯកជន។ អ្នកកាសែតឯករាជ្យមានវត្តមាន ហើយពួកគេភាគច្រើនរក្សាបាននូវបទដ្ឋានខ្ពស់នៃសុចរិតភាពសារព័ត៌មាន ប៉ុន្តែពួកគេក៏ប្រឈមមុខនឹងបញ្ហាជាច្រើនដែរ។ នៅចុងឆ្នាំ២០១៧ រាល់ស្ថានីយ៍វិទ្យុទាំងអស់ដែលបានផ្សាយបន្តពីវិទ្យុអាស៊ីសេរី(RFA) និងសម្លេងសហរដ្ឋអាមេរិច(VOA) ត្រូវបានហាមឃាត់មិនឱ្យចាក់ផ្សាយកម្មវិធីទាំងនោះបន្តស្របពេលដែលមានការបិទនូវកាសែតជាភាសាអង់គ្លេសធំបំផុតមួយ សម្រាប់ការដំណើរការមិនត្រឹមត្រូវដោយមិនបង់ពន្ធជូនរដ្ឋ។[38] អង្គការសង្គមស៊ីវិលមួយចំនួនដែលពីមុនបានចូលរួមក្នុងការរាយការណ៍អំពីសិទ្ធិមនុស្ស និងស្វែងរកមតិគាំទ្រ អាចមានលទ្ធភាពធ្វើឱ្យក្រុមហ៊ុនឯកជនប្រកាន់នូវសុចរិតភាពធុរកិច្ច។ កន្លងមក ពួកគេបានធ្វើឱ្យក្រុមហ៊ុនមួយចំនួនទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស ជាពិសេស ទាក់ទងនឹងសិទ្ធិដីធ្លី។

[35] The Cambodia Daily, 24 September 2008.

[36] CCC Strategy 2016-2021

[37] Reporters Without Borders, 2016

[38] HRW, 2017

## អនុសាសន៍សម្រាប់សង្គមស៊ីវិល

អនុសាសន៍រយៈពេលខ្លី៖

- អង្គការសង្គមស៊ីវិល គួរចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដើម្បីផ្តល់ការបណ្តុះបណ្តាលក្នុងការស៊ើបអង្កេត និងការចងក្រងឯកសារអំពីអំពើពុករលួយក្នុងវិស័យឯកជន និងបញ្ហាសុចរិតភាពធុរកិច្ច។
- អង្គការសង្គមស៊ីវិល គួរបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជនលើគំនិតផ្តួចផ្តើមដែលលើកកម្ពស់សុចរិតភាពធុរកិច្ច។
- សង្គមស៊ីវិល គួរទទួលស្គាល់ និងផ្តល់រង្វាន់ដល់ធុរកិច្ចទាំងឡាយណាដែលលើកកម្ពស់ការប្រឆាំងអំពើពុករលួយ និងសុចរិតភាពធុរកិច្ច។
- អង្គការសង្គមស៊ីវិល គួរតាមដានឱ្យបានជាប់លាប់ និងរាយការណ៍ពីវិស័យឯកជន ដោយផ្តោតលើការប្រឆាំងអំពើពុករលួយ និងសុចរិតភាពធុរកិច្ច។

អនុសាសន៍រយៈពេលវែង៖

- សង្គមស៊ីវិល និងវិស័យឯកជន គួរតែសម្របសម្រួលដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមដែលបង្កើនសុចរិតភាពធុរកិច្ច រួមទាំងចូលរួមធ្វើការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយដែលបង្កើនសុចរិតភាព តម្លាភាព និងគណនេយ្យភាព។
- សង្គមស៊ីវិល គប្បីពិគ្រោះយោបល់ និងចូលរួមជាមួយវិស័យឯកជន និងវិស័យសាធារណៈស្តីពីការអនុម័តខ្លឹមសារច្បាប់សំខាន់ៗ ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព ដូចជា សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង សេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ និងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី។
- ប្រព័ន្ធផ្សព្វផ្សាយ គួរបន្តកំណត់ប្រភពចំណូលឯករាជ្យសម្រាប់ស្ថាប័នរបស់ពួកគេ ដើម្បីរក្សា និងលើកកម្ពស់ឯករាជ្យភាព។
- ប្រព័ន្ធផ្សព្វផ្សាយ គួរតែបង្កើនការស៊ើបអង្កេត និងរាយការណ៍អំពីសុចរិតភាពធុរកិច្ច។

## អ្វីដែលអ្នកអាចធ្វើបាន?

- លើកទឹកចិត្តក្រុមហ៊ុនដែលអ្នកចូលចិត្ត ឱ្យបោះពុម្ពផ្សាយក្រមវិជ្ជាជីវៈ និងគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ នៅលើគេហទំព័ររបស់ពួកគេ។
- គាំទ្រក្រុមហ៊ុននានាដែលប្រកាសជាសាធារណៈថា ពួកគេប្រឆាំងនឹងអំពើពុករលួយ ហើយត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនដែលលើកកម្ពស់ការប្តេជ្ញាចិត្តរបស់ពួកគេចំពោះសុចរិតភាពធុរកិច្ច។
- រាយការណ៍ពីអំពើពុករលួយទៅអង្គភាពប្រឆាំងអំពើពុករលួយ។

# ឯកសារយោង


1. សទ្ទានុក្រមប្រឆាំងអំពើពុករលួយ
2. Thompson & Walker, 1998
3. TI-BICA Supplement 1: Assessment, 2016, p.12
4. UNCAC, Articles 14, 23.
5. TI-BICA Supplement 2: Indicators, 2016
6. TI-BICA Supplement 2: Indicators, 2016
7. WTO Cambodia; UNODC, UNCAC Ratification
8. ACL, 2010. Chap. 6.
9. The Phnom Penh Post, 6 January 2012,
10. The Phnom Penh Post. 5 January 2017.
11. TI-NISA Cambodia 2014, p. 6.
12. US State Department, 2017
13. The Phnom Penh Post, 5 October 2015
14. The Cambodia Daily, 11 January 2017.
15. Expert Interview 13.
16. The Phnom Penh Post, 30 June 2016
17. ACL, 2010. Art. 17.
18. KPMG, 2016
19. LEMNA 2013, Article 37
20. LEMNA 2013, Article 37
21. Procurement Manual 1, Reg. 4.7.
22. Procurement Manual 1, Reg. 6.2.1
23. Procurement Manual 1, Reg. 4.3.5.
24. Procurement Manual 1, Reg. 14.2.2.
25. Procurement Manual 1, Reg. 17.1
26. EUROCHAM, 2017
27. WBG Enterprise Survey, 2016
28. ASYCUDA Project
29. US State Department Investment Climate, 2017
30. FASMEC Survey, 2017
31. FASMEC Survey, 2017
32. EUROCHAM,Tax Committee, 2017
33. LCE, 2005, Article 127
34. Prakas No. 013, Article 3
35. The Cambodia Daily, 24 September 2008.
36. CCC Strategy 2016-2021
37. Reporters Without Borders, 2016
38. HRW, 2017